បោះពុម្ពនៅរោងពុម្ព ទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ១.៥០០ ច្បាប់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*****

ឆ្នាំទី ៧ លេខ ៩ ថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩

# រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសម្រេច
- សារាចរ

# មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ១-ព្រះរាជក្រម


០៨-៣-១៩៩៩ -ព្រះរាជក្រម នស/រកម/០៣៩៩/០១ ប្រកាសអោយប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១.១២.១៣.១៨.២២.២៤.២៦.២៨.៣០.៣៤.៥១.៩០.៩១.៩៣ និងមាត្រាទាំងឡាយ នៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃទី ៤ ខែ មីនា ឆ្នាំ ១៩៩៩ ៣១១


### ២-ព្រះរាជក្រឹត្យ


៤-៣-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/០៣៩៩/៣៧ តែងតាំងឯកឧត្តម សរិត រ៉េត , ញ៉ិក វណ្ណារ៉ា , សុខ សេងយ៉ាន , លោកជំទាវ ស៊ូ សូមា ជាទីប្រឹក្សា និង ឧបការីរបស់ឯកឧត្តម តុល ឡោះ ឧបនាយករដ្ឋមន្ត្រី ៣២៩

៥-៣-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/០៣៩៩/៣៨ តែងតាំង លោកឡូវ ហ៊ឹង ជាឧកញ៉ា ៣៣០

៥-៣-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/០៣៩៩/៣៩ តែងតាំងទីប្រឹក្សាក្រសួងមហាផ្ទៃ ៣៣០

៥-៣-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/០៣៩៩/៤០ តែងតាំង ឯកឧត្តម មាស កេត្តកៃមីរ៉ាន ជាទីប្រឹក្សាអមក្រសួង សាធារណការ និងដឹកជញ្ជូន ៣៣១

៦-៣-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/០៣៩៩/៤១ តែងតាំង ស្តេចក្រុមឃុន នរោត្តម សិរីវុឌ្ឍ ជាឧត្តមក្រុមប្រឹក្សារបស់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ៣៣២


## II- រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


០១-៣-១៩៩៩ -អនុក្រឹត្យ លេខ ៥០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៣៣

០១-៣-១៩៩៩ -អនុក្រឹត្យ លេខ ៥១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៣៤

០១-៣-១៩៩៩ -អនុក្រឹត្យ លេខ ៥២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៣៥

០១-៣-១៩៩៩ -អនុក្រឹត្យ លេខ ៥៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៣៦

| | | | |
|---|---|---|---|
| ០១-៣-១៩៩៩ | -អនុក្រឹត្យ លេខ ៥៤ អនក្រ.គត | ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ | ៣៣៧ |
| ០១-៣-១៩៩៩ | -អនុក្រឹត្យ លេខ ៥៥ អនក្រ.គត | ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ | ៣៣៨ |
| ០១-៣-១៩៩៩ | -អនុក្រឹត្យ លេខ ៥៦ អនក្រ.គត | ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ | ៣៣៩ |
| ០២-៣-១៩៩៩ | -អនុក្រឹត្យ លេខ ៥៧ អនក្រ.គត | ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ | ៣៤០ |
| ០២-៣-១៩៩៩ | -អនុក្រឹត្យ លេខ ៥៨ អនក្រ.គត | ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ | ៣៤១ |
| ០២-៣-១៩៩៩ | -អនុក្រឹត្យ លេខ ៥៩ អនក្រ.គត | ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ | ៣៤២ |
| ០២-៣-១៩៩៩ | -អនុក្រឹត្យ លេខ ៦០ អនក្រ.គត | ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ | ៣៤៣ |
| ០២-៣-១៩៩៩ | -អនុក្រឹត្យ លេខ ៦១ អនក្រ.គត | ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ | ៣៤៤ |
| ០២-៣-១៩៩៩ | -អនុក្រឹត្យ លេខ ៦២ អនក្រ.គត | ស្តីពីការតែងតាំងមន្ត្រីរាជការ | ៣៤៥ |
| ០៤-៣-១៩៩៩ | -អនុក្រឹត្យ លេខ ៦៣ អនក្រ.គត | ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ | ៣៤៦ |
| ០៤-៣-១៩៩៩ | -អនុក្រឹត្យ លេខ ៦៤ អនក្រ.គត | ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ | ៣៤៧ |
| ០៥-៣-១៩៩៩ | -អនុក្រឹត្យ លេខ ៦៥ អនក្រ.គត | ស្តីពីការតែងតាំងមន្ត្រីរាជការ | ៣៤៨ |


## III- ការងារមណ្ឌលក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

#### ប្រកាស


០៥-៣-១៩៩៩ – ប្រកាស លេខ ៦៦៦ ពណ.ខកល ៩៩ ស្តីពីការកែប្រែមួយចំនួនចំពោះប្រកាសលេខ ៣៦០ MOC/M99 ចុះថ្ងៃទី១០-២-១៩៩៩ អំពីការបង្កើតគណៈកម្មការគ្រប់គ្រងកូតា សំរាប់ការនាំចេញវាយនភ័ណ្ឌ និងផលិតផលវាយនភ័ណ្ឌ ដែលជាកម្មវត្ថុនៃការកំណត់បរិមាណដោយសហរដ្ឋអាមេរិក ៣៤៩


### ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល

#### ប្រកាស


០៣-៣-១៩៩៩ -ប្រកាស លេខ ២៧៣ ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន គុបកូស ខេមបូឌា កូអិលធីឌី តំណាងដោយលោក LEE KWANG HEE សញ្ជាតិ កូរ៉េ បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ ៣៥១

០៣-៣-១៩៩៩ -ប្រកាស លេខ ២៧៤ ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន ហ្វ្រង់កូនីធីងហ្វាក់តរី អែលធីឌី តំណាងដោយលោក CHEONG CHI HOU សញ្ជាតិ ព័រទុយហ្គេ បង្កើតរោងចក្រកាត់ដេរ និង ចាក់សំលៀកបំពាក់នាំចេញ ។ ៣៥៣

## ៣-ទីស្តីការរដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

### ប្រកាស


០១-៣-១៩៩៩ -ប្រកាស លេខ ០៤ ប្រក ស្តីពីការបញ្ចូលក្របខ័ណ្ឌ មន្ត្រីរាជការ ៣៩៩

០២-៣-១៩៩៩ -ប្រកាស លេខ ០៥ ប្រក ស្តីពីការបញ្ចូលក្របខ័ណ្ឌ មន្ត្រីរាជការ ៤០៥


## ៤-ទីស្តីការរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

### ១-ប្រកាស


០៤-៣-១៩៩៩ -ប្រកាស លេខ ១៤៩ អយក.ប្រក. ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃការប្រលងសញ្ញាបត្រ មធ្យមសិក្សាបឋមភូមិ ៤១៥


### ២-សារាចរណែនាំ


០៤-៣-១៩៩៩ -សារាចរណែនាំ លេខ ០១ អយក.សរណន ស្តីពីការប្រលងបញ្ចប់គ្រប់ភូមិសិក្សា ផ្នែកចំណេះទូទៅបំពេញវិជ្ជាសាធារណៈ និង ឯកជន ៤២១

០៤-៣-១៩៩៩ -សារាចរណែនាំ លេខ ០២ អយក.សរណន ស្តីពីការរៀបចំប្រលងសញ្ញាបត្រ ចំណេះទូទៅនិងបំពេញវិជ្ជា ៤២៧


## ៥-ទីស្តីការរដ្ឋមន្ត្រី ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាល វិជ្ជាជីវៈ និងយុវនីតិសម្បទា

### ប្រកាស


០១-៣-១៩៩៩ -ប្រកាស លេខ ៤០ សកបយ ស្តីពីការបន្ថែមម៉ោងធ្វើការ ក្រៅពីថិរវេលាធ្វើការធម្មតា ៤៣៤

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ១-ព្រះរាជក្រម

### ព្រះរាជក្រម នស/រកម/០៣៩៩/០១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និគរោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * * *

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានទ្រង់យល់សម័យប្រជុំវិសាមញ្ញពេញអង្គ នៃរដ្ឋសភា នៅថ្ងៃទី២-៣-៤- ខែ មីនា ឆ្នាំ ១៩៩៩

-យោងតាមសំណើរបស់ ប្រធានរដ្ឋសភា ចុះថ្ងៃទី ៦ ខែ មីនា ឆ្នាំ ១៩៩៩

ត្រាស់បង្គាប់

**មាត្រា ១ .-** ប្រកាសអោយប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្ម មាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រា ទាំងឡាយ នៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃទី៤ ខែ មីនា ឆ្នាំ ១៩៩៩

**មាត្រា ២ .-** ព្រះរាជក្រមនេះចូលជាធរមានច្បាប់ ចាប់ពីពេលឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩

ព្រះហស្ថលេខា

នរោត្តម សីហនុ

***

# ច្បាប់ធម្មនុញ្ញ
## ស្តីពី
## វិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣
## និង
## មាត្រាទាំងឡាយ នៃជំពូកទី ៨
## ដល់
## ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ

**មាត្រាតែមួយ .-** មាត្រា១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយ នៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ ត្រូវបានកែប្រែដូចតទៅ ៖

**មាត្រា ១១.- ថ្មី**

ក្នុងករណីដែលព្រះមហាក្សត្រពុំអាចបំពេញព្រះរាជភារៈ ជាព្រះប្រមុខរដ្ឋបានដូចធម្មតាដោយព្រះអង្គប្រឈួនជាទម្ងន់ មានការបញ្ជាក់ដោយក្រុមគ្រូពេទ្យជំនាញជ្រើសរើសដោយប្រធាន ព្រឹទ្ធសភា ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នោះប្រធានព្រឹទ្ធសភាបំពេញភារកិច្ចប្រមុខរដ្ឋជំនួសព្រះអង្គ ក្នុងឋានៈជាព្រះរាជានុសិទ្ធិ ។

ក្នុងករណីដែលប្រធានព្រឹទ្ធសភា ពុំមានលទ្ធភាពបំពេញភារកិច្ចជា ប្រមុខរដ្ឋជំនួសព្រះមហាក្សត្រ ក្នុងឋានៈជាព្រះរាជានុសិទ្ធិ ពេលព្រះអង្គទ្រង់ប្រឈួនជាទម្ងន់ ដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ ប្រធានរដ្ឋសភាជាអ្នកបំពេញភារកិច្ចនេះ ។

តំណែងជាប្រមុខរដ្ឋជំនួសព្រះមហាក្សត្រក្នុងឋានៈជាព្រះរាជានុសិទ្ធិនេះ អាចនឹងផ្ទេរឲ្យទៅជនផ្សេងទៀត ក្នុងករណីដូចដែលបានចែងក្នុងវាក្យខ័ណ្ឌខាងលើ តាមឋានានុក្រមដូចតទៅ :

ក- អនុប្រធានទី ១ ព្រឹទ្ធសភា

ខ- អនុប្រធានទី ១ រដ្ឋសភា

គ- អនុប្រធានទី ២ ព្រឹទ្ធសភា

ឃ-អនុប្រធានទី ២ រដ្ឋសភា

**មាត្រា ១២.- ថ្មី**

នៅពេលព្រះមហាក្សត្រទ្រង់ចូលទីវង្គត់ ប្រធានព្រឹទ្ធសភាទទួលភារកិច្ច ជាប្រមុខរដ្ឋស្តីទីក្នុងឋានៈជាព្រះរាជានុសិទ្ធិ នៃព្រះរាជាណាចក្រកម្ពុជា ។

ក្នុងករណីដែលប្រធានព្រឹទ្ធសភាពុំមានលទ្ធភាពបំពេញភារកិច្ចជាប្រមុខរដ្ឋស្ដីទី ជំនួសព្រះមហាក្សត្រ ក្នុងពេលព្រះអង្គចូលទីវង្គត ការទទួលភារកិច្ចជាប្រមុខរដ្ឋស្ដីទី ក្នុងឋានៈជាព្រះរាជានុសិទ្ធិ ត្រូវអនុវត្តតាមវាក្យខ័ណ្ឌទី២ និងទី៣ នៃមាត្រា១១ថ្មី ។

**មាត្រា ១៣.- ថ្មី**

ក្នុងរយៈពេល ៧ថ្ងៃយ៉ាងយូរ ព្រះមហាក្សត្រថ្មីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សារាជសម្បត្តិ ។

សមាសភាពនៃក្រុមប្រឹក្សារាជសម្បត្តិមាន ៖

- ប្រធានព្រឹទ្ធសភា
- ប្រធានរដ្ឋសភា
- នាយករដ្ឋមន្ត្រី
- សម្ដេចព្រះសង្ឃរាជ គណៈមហានិកាយ និងគណៈធម្មយុត្តិកនិកាយ
- អនុប្រធានទី១ និងអនុប្រធានទី២ ព្រឹទ្ធសភា
- អនុប្រធានទី១ និងអនុប្រធានទី២ រដ្ឋសភា

ការរៀបចំ និងការប្រព្រឹត្តិទៅ នៃក្រុមប្រឹក្សារាជសម្បត្តិ នឹងមានកំណត់ក្នុងច្បាប់មួយ ។

**មាត្រា ១៤.- ថ្មី**

ព្រះមហាក្សត្រ ព្រះអង្គទ្រង់ទាក់ទងជាមួយព្រឹទ្ធសភា និងរដ្ឋសភាដោយព្រះរាជសារ ។

ព្រះរាជសារនេះ ព្រឹទ្ធសភានិងរដ្ឋសភាមិនអាចយកទៅជជែកពិភាក្សាឡើយ ។

**មាត្រា ២២ .- ថ្មី**

នៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ ព្រះមហាក្សត្រទ្រង់ប្រកាសប្រាប់ប្រជាជនជាសាធារណៈ ដាក់ប្រទេសជាតិស្ថិតនៅក្នុងភាពអាសន្ន ក្រោយពីបានមតិឯកភាពពីនាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភា ។

**មាត្រា ២៤ .- ថ្មី**

ព្រះមហាក្សត្រទ្រង់គង់ជាព្រះអធិបតីនៃឧត្ដមក្រុមប្រឹក្សាការពារជាតិ ដែលនឹងត្រូវបង្កើតឡើងដោយច្បាប់មួយ ។

ព្រះមហាក្សត្រទ្រង់ប្រកាសសង្គ្រាម ក្រោយការអនុម័តរបស់រដ្ឋសភា និង ព្រឹទ្ធសភា ។

**មាត្រា ២៦ .- ថ្មី**

ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្ថលេខាលើសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ ហើយទ្រង់ប្រទានសច្ចាប័នលើសន្ធិសញ្ញានិងអនុសញ្ញាទាំងនេះ ក្រោយបានទទួលការអនុម័តរបស់ព្រមពីរដ្ឋសភា និង ព្រឹទ្ធសភា ។

**មាត្រា ២៨ .- ថ្មី**

ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសអោយប្រើរដ្ឋធម្មនុញ្ញ ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ និងទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យ តាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី ។

ក្នុងពេលដែលព្រះមហាក្សត្រប្រឈួន ហើយត្រូវព្យាបាលព្រះរោគនៅបរទេស ក្នុងពេលនោះ ព្រះមហាក្សត្រមានសិទ្ធិផ្ទេរអំណាច ឡាយព្រះហស្តលេខានៅលើព្រះរាជក្រម ឬព្រះរាជក្រឹត្យខាងលើនេះ ទៅប្រមុខរដ្ឋស្តីទីចុះហត្ថលេខាជំនួសដោយព្រះរាជសារប្រគល់សិទ្ធិ ។

**មាត្រា ៣០ .- ថ្មី**

ក្នុងរយៈពេលព្រះមហាក្សត្រអវត្តមាន ប្រធានព្រឹទ្ធសភា ទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ។

ក្នុងករណីដែលប្រធានព្រឹទ្ធសភា ពុំមានលទ្ធភាពបំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទីជំនួសព្រះមហាក្សត្រ ពេលព្រះអង្គទ្រង់អវត្តមាន ការទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ត្រូវអនុវត្តតាមវាក្យខណ្ឌទី ២ និងទី ៣ នៃមាត្រា ១១ថ្មី ។

**មាត្រា ៣៤ .-ថ្មី**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះអោយគេបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ១៨ឆ្នាំ មានសិទ្ធិបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ២៥ឆ្នាំ អាចឈរឈ្មោះអោយគេបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ៤០ឆ្នាំ អាចឈរឈ្មោះអោយគេបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភា ។

បទប្បញ្ញត្តិបន្ថយសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះអោយគេបោះឆ្នោត ត្រូវចែងក្នុងច្បាប់បោះឆ្នោត ។

**មាត្រា ៥១ .-ថ្មី**

ព្រះរាជាណាចក្រកម្ពុជាអនុវត្តនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ។

អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួន តាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាលនិងសាលាជំរះក្តី ។

អំណាចបែងចែកដាច់ពីគ្នារវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។

**មាត្រា ៩០ .-ថ្មី**

រដ្ឋសភាជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួន ដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ។

រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការអោយរដ្ឋខ្ចីប្រាក់ពីគេ ការអោយរដ្ឋអោយប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ ឬ លុបចោលពន្ធដារ ។

រដ្ឋសភាអោយសេចក្ដីយល់ព្រមចំពោះគណនីរដ្ឋបាល ។

រដ្ឋសភាអនុម័តច្បាប់ ស្ដីពីការលើកលែងទោសជាទូទៅ ។

រដ្ឋសភាអនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ ។

រដ្ឋសភាអនុម័តច្បាប់ ស្ដីពីការប្រកាសសង្គ្រាម ។

ការអនុម័តខាងលើនេះ ប្រព្រឹត្តទៅដោយមតិភាគច្រើន ដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាល តាមមតិភាគច្រើន ពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ៩១ .-ថ្មី**

សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងនាយករដ្ឋមន្ត្រី មានសិទ្ធិផ្ដួចផ្ដើមគំនិតធ្វើច្បាប់ ។

តំណាងរាស្ត្រមានសិទ្ធិស្នើធ្វើវិសោធនកម្មច្បាប់ ប៉ុន្តែសំណើនេះមិនអាចទទួលយកបានទេ បើវិសោធនកម្មនោះសំដៅបន្ថយប្រាក់ចំណូលសាធារណៈ ឬបន្ថែមបន្ទុកលើប្រជាពលរដ្ឋ ។

**មាត្រា ៩៣ .-ថ្មី**

ច្បាប់ដែលរដ្ឋសភាបានអនុម័តនិងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ ហើយត្រូវបានព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាប្រកាសអោយប្រើ ត្រូវចូលជាធរមាននៅរាជធានីភ្នំពេញក្នុងរយៈពេលដប់ថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសអោយប្រើ និងនៅទូទាំងប្រទេសក្នុងរយៈពេលម្ភៃថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសអោយប្រើ ។ ប៉ុន្តែបើច្បាប់នេះបានចែងថាជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេស ក្រោយថ្ងៃប្រកាសអោយប្រើ ។

ច្បាប់ដែលព្រះមហាក្សត្រទ្រង់បានឡាយព្រះហស្តលេខាប្រកាសអោយប្រើ ត្រូវចុះក្នុងរាជកិច្ច និងផ្សព្វផ្សាយនៅទូទាំងប្រទេស អោយទាន់តាមពេលកំណត់ខាងលើ ។

## ជំពូកទី ៨ ថ្មី
## អំពី
# ព្រឹទ្ធសភា

**មាត្រា ៩៩ .-ថ្មី**

ព្រឹទ្ធសភាជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួន ដូចមានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ។

ព្រឹទ្ធសភាមានចំនួនសមាជិកយ៉ាងច្រើនស្មើនឹងពាក់កណ្ដាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

សមាជិកព្រឹទ្ធសភាត្រូវចាត់តាំងខ្លះនិងត្រូវជ្រើសតាំងដោយការបោះឆ្នោតអសកលខ្លះ ។

សមាជិកព្រឹទ្ធសភាអាចត្រូវបានចាត់តាំង និងជ្រើសតាំងសាជាថ្មីបាន ។ អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនព្រឹទ្ធសភា គឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច ៤០ឆ្នាំ មានសញ្ជាតិខ្មែរតាំងពីកំណើត ។

មាត្រា ១០០ .-ថ្មី

សមាជិកព្រឹទ្ធសភាចំនួន ២រូប ត្រូវបានចាត់តាំងដោយ ព្រះមហាក្សត្រ ។

សមាជិកព្រឹទ្ធសភាចំនួន ២រូប ត្រូវបានរដ្ឋសភាជ្រើសតាំងតាមមតិភាគច្រើន ដោយប្រៀប ។

រីឯសមាជិកព្រឹទ្ធសភាឯទៀត ត្រូវបានជ្រើសតាំងដោយការបោះឆ្នោតអសកល ។

មាត្រា ១០១ .-ថ្មី

ការរៀបចំ បែបបទ និងការប្រព្រឹត្តិទៅនៃការចាត់តាំង និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ព្រមទាំងការកំណត់អំពីអ្នកបោះឆ្នោត អង្គបោះឆ្នោត និងមណ្ឌលបោះឆ្នោត ត្រូវចែងក្នុងច្បាប់មួយ ។

មាត្រា ១០២ .-ថ្មី

នីតិកាលរបស់ព្រឹទ្ធសភាមានកំណត់ ៦ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលព្រឹទ្ធសភាថ្មីចូលកាន់តំណែង ។

ក្នុងពេលមានសង្គ្រាម ឬ ក្នុងកាលៈទេសៈពិសេសដទៃទៀត ដែលមិនអាចធ្វើការបោះឆ្នោតកើត ព្រឹទ្ធសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួនមួយដងបានមួយឆ្នាំ តាមសំណើរបស់ព្រះមហាក្សត្រ ។

ការប្រកាសបន្តនីតិកាលរបស់ព្រឹទ្ធសភា ត្រូវសំរេចដោយមតិយល់ព្រមពីរភាគបីយ៉ាងតិច នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ក្នុងកាលៈទេសៈដូចបានរៀបរាប់ខាងលើ ព្រឹទ្ធសភាប្រជុំរាល់ថ្ងៃជាប់ជាប្រចាំ ។ ព្រឹទ្ធសភាមានសិទ្ធិសំរេចបញ្ចប់កាលៈទេសៈពិសេសខាងលើនេះ កាលបើសភាពការណ៍អនុញ្ញាត ។

បើព្រឹទ្ធសភាមិនអាចប្រជុំបានទេ ដោយមូលហេតុចាំបាច់ ជាអាទិ៍នៅពេលដែលកំលាំងបរទេសចូលមកកាន់កាប់ទឹកដី ការប្រកាសភាពអាសន្នត្រូវបន្តទៅមុខជាស្វ័យប្រវត្តិ ។

មាត្រា ១០៣ .-ថ្មី

អាណត្តិនៃសមាជិកព្រឹទ្ធសភាមានវិសមិតភាពជាមួយការបំពេញមុខងារសាធារណៈជាសកម្មជាមួយមុខងារជាតំណាងរាស្ត្រនិងជាមួយមុខងារជាសមាជិកស្ថាប័នដទៃទៀត ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។

មាត្រា ១០៤ .-ថ្មី

សមាជិកព្រឹទ្ធសភា មានអភ័យឯកសិទ្ធិសភា ។

សមាជិកព្រឹទ្ធសភារូបណាក៏ដោយមិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬបង្ខាំងខ្លួនដោយហេតុពីបានសំដែងយោបល់ ឬ បញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួន សមាជិកណាមួយនៃព្រឹទ្ធសភា នឹងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីព្រឹទ្ធសភា ឬពីគណៈកម្មាធិការ អចិន្ត្រៃយ៍របស់ព្រឹទ្ធសភា ក្នុងចន្លោះសម័យប្រជុំនៃព្រឹទ្ធសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ។ ក្នុងករណីចុងក្រោយនេះ ក្រសួងមានសមត្ថកិច្ច ត្រូវធ្វើសេចក្តីរាយការណ៍ ជូនព្រឹទ្ធសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភាជាបន្ទាន់ដើម្បីសំរេច ។

សេចក្តីសំរេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភាត្រូវដាក់ជូនសម័យប្រជុំព្រឹទ្ធសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបីនៃសមាជិកព្រឹទ្ធសភាទាំងមូល ។

ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់សមាជិកព្រឹទ្ធសភាណាមួយ ត្រូវផ្អាក ប្រសិនបើព្រឹទ្ធសភាបានបញ្ចេញមតិអោយផ្អាកតាមមតិភាគច្រើន បីភាគបួននៃសមាជិកព្រឹទ្ធសភាទាំងមូល ។

**មាត្រា ១០៥ .-ថ្មី**

ព្រឹទ្ធសភាមានថវិកាស្វយ័តសំរាប់ដំណើរការ ។

សមាជិកព្រឹទ្ធសភាត្រូវទទួលប្រាក់បំណាច់ ។

**មាត្រា ១០៦ .-ថ្មី**

ព្រឹទ្ធសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរ ក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

មុនចាប់ផ្តើមការងាររបស់ខ្លួន ព្រឹទ្ធសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ និងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវប្រធាន អនុប្រធានព្រឹទ្ធសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់ព្រឹទ្ធសភា ដោយមតិភាគច្រើនពីរភាគបីនៃសមាជិកព្រឹទ្ធសភាទាំងមូល ។

សមាជិកព្រឹទ្ធសភាទាំងអស់ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែងដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៧ នៃរដ្ឋធម្មនុញ្ញ ។

**មាត្រា ១០៧ .-ថ្មី**

ព្រឹទ្ធសភាប្រជុំជាសាមញ្ញពីរដងក្នុងមួយឆ្នាំ ។

សម័យប្រជុំនីមួយៗមានថេរវេលាយ៉ាងតិចបីខែ ។ បើមានសំណូមពរពីព្រះមហាក្សត្រ ឬសេចក្តីស្នើសុំពីនាយករដ្ឋមន្ត្រី ឬពីសមាជិកព្រឹទ្ធសភាចំនួនមួយភាគបីយ៉ាងតិច ព្រឹទ្ធសភាកោះប្រជុំជាវិសាមញ្ញ ។

**មាត្រា ១០៨ .-ថ្មី**

នៅចន្លោះសម័យប្រជុំរបស់ព្រឹទ្ធសភា គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភាទទួលភារកិច្ចចាត់ចែងការងារ ។

គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភា រួមមាន ៖ ប្រធានព្រឹទ្ធសភា អនុប្រធានព្រឹទ្ធសភា និងប្រធានគណៈកម្មការទាំងអស់របស់ព្រឹទ្ធសភា ។

មាត្រា ១០៩ .-ថ្មី

សម័យប្រជុំព្រឹទ្ធសភាត្រូវធ្វើនៅរាជធានីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងសាលប្រជុំរបស់ព្រឹទ្ធសភា លើកលែងតែមានការសំរេចផ្សេងចុះក្នុងលិខិតកោះប្រជុំ ដោយកាលៈទេសៈតម្រូវ ។

ក្រៅពីករណីខាងលើនិងក្រៅពីកន្លែង និងកាលបរិច្ឆេទដែលកំណត់ក្នុងសេចក្តីអញ្ជើញ ការប្រជុំណាក៏ដោយរបស់ព្រឹទ្ធសភាត្រូវទុកជាខុសច្បាប់ ហើយអសារបង់សូន្យពេញលក្ខណៈ ។ ទទួលភារកិច្ចចាត់ចែងការងារ ។

មាត្រា ១១០ .-ថ្មី

ប្រធានព្រឹទ្ធសភាដឹកនាំអង្គប្រជុំរបស់ព្រឹទ្ធសភា ទទួលអាញ្ញត្តិច្បាប់ និងសេចក្តីសំរេចចិត្តទាំងឡាយដែលព្រឹទ្ធសភាបានអនុម័ត រ៉ាប់រងការអនុវត្តន៏បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា និងចាត់ចែងការទាក់ទងអន្តរជាតិទាំងឡាយរបស់ព្រឹទ្ធសភា ។

ក្នុងករណីដែលប្រធានព្រឹទ្ធសភាមានធុរៈ មិនអាចបំពេញមុខងារបាន ដោយហេតុមកពីមានជម្ងឺ ឬ បំពេញមុខងារជាប្រមុខរដ្ឋស្តីទី ឬ ជាព្រះរាជានុសិទ្ធិឬបំពេញបេសកកម្មនៅបរទេស អនុប្រធានព្រឹទ្ធសភាមួយរូប ត្រូវទទួលភារកិច្ចចាត់ចែងការងារជំនួស ។

ក្នុងករណីដែលប្រធាន ឬ អនុប្រធានព្រឹទ្ធសភាលាលែងពីមុខតំណែង ឬ ទទួលអនិច្ចកម្ម ព្រឹទ្ធសភាត្រូវបោះឆ្នោតជ្រើសតាំងប្រធាន ឬ អនុប្រធានថ្មី ។

មាត្រា ១១១ .-ថ្មី

ការប្រជុំព្រឹទ្ធសភា ត្រូវធ្វើជាសាធារណៈ ។

ព្រឹទ្ធសភាអាចប្រជុំជាសំងាត់បានតាមការស្នើពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិចពីព្រះមហាក្សត្រ ពីនាយករដ្ឋមន្ត្រី ឬ ពីប្រធានរដ្ឋសភា ។

ការប្រជុំព្រឹទ្ធសភានឹងយកជាការបាន លុះត្រាតែមានកូរ៉ុមប្រាំពីរភាគដប់ នៃសមាជិកព្រឹទ្ធសភាទាំងមូល ។

ចំនួនសំឡេងដែលតម្រូវសំរាប់រដ្ឋសភាអនុម័តយល់ព្រម ហើយដែលបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ត្រូវយកមកប្រើសំរាប់ព្រឹទ្ធសភាផងដែរ ។

មាត្រា ១១២ .-ថ្មី

ព្រឹទ្ធសភា មានភារកិច្ចសំរបសំរួលការងាររវាងរដ្ឋសភា និងរដ្ឋាភិបាល ។

មាត្រា ១១៣ .-ថ្មី

ព្រឹទ្ធសភាពិនិត្យហើយអោយយោបល់ក្នុងរយៈពេលមួយខែយ៉ាងយូរ លើសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមលើកដំបូងរួចហើយ ព្រមទាំងលើបញ្ហាទាំងពួងដែលរដ្ឋសភាបានដាក់អោយពិនិត្យ ។ បើជាការប្រញាប់ រយៈពេលនោះត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ ។

បើព្រឹទ្ធសភាបានអោយយោបល់យល់ព្រម ឬ ពុំបានអោយយោបល់សោះ ក្នុងរយៈពេលដែលមានកំណត់ទុកហើយនោះទេ ច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមហើយនោះ នឹងត្រូវបានយកទៅប្រកាសអោយប្រើ ។

បើព្រឹទ្ធសភាសុំអោយកែសំរួលសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់នោះ រដ្ឋសភាត្រូវយកមកពិចារណាភ្លាមជាលើកទី២ ។ រដ្ឋសភាត្រូវពិនិត្យ និងសំរេចតែត្រង់បទប្បញ្ញត្តិឬចំណុចណាដែលព្រឹទ្ធសភាសុំអោយកែសំរួល ដោយបដិសេធចោលទាំងមូល ឬទុកជាបានការខ្លះ ។

ការបង្វិលទៅបង្វិលមករវាងព្រឹទ្ធសភានិងរដ្ឋសភា ត្រូវធ្វើតែក្នុងរយៈពេលមួយខែ ។ រយៈពេលនេះត្រូវបន្ថយមកត្រឹមដប់ថ្ងៃ បើត្រូវពិនិត្យសំរេចពីថវិកាជាតិ និងហិរញ្ញវត្ថុ ហើយមកត្រឹមតែពីរថ្ងៃ បើជាការប្រញាប់ ។

បើរដ្ឋសភាទុកអោយហួសរយៈពេលកំណត់ ឬ ពន្យារពេលដែលកំណត់ទុកសំរាប់ពិនិត្យនោះ រយៈពេលជាគោលការណ៍សំរាប់រដ្ឋសភា និងព្រឹទ្ធសភា ត្រូវបន្ថែមអោយស្មើគ្នាដែរ ។

បើព្រឹទ្ធសភាបដិសេធសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះជាអសារបង់ រដ្ឋសភាមិនអាចនឹងយកមកពិចារណាជាលើកទីពីរបាន មុនរយៈពេលមួយខែទេ ។ រយៈពេលនេះត្រូវបន្ថយមកត្រឹមដប់ប្រាំថ្ងៃ បើពិនិត្យពីថវិកាជាតិ និងហិរញ្ញវត្ថុ ហើយមកត្រឹមតែបួនថ្ងៃបើជាការប្រញាប់ ។

ក្នុងការពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ជាលើកទី២នេះ រដ្ឋសភាត្រូវអនុម័តដោយវិធីបោះឆ្នោតចំហ និងយកតាមមតិភាគច្រើនដាច់ខាត ។

សេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ណាដែលបានសំរេចដូចខាងលើនេះហើយនោះ នឹងត្រូវបានយកទៅប្រកាសអោយប្រើ ។

**មាត្រា ១១៤ .–ថ្មី**

ព្រឹទ្ធសភាបង្កើតគណៈកម្មការផ្សេងៗដែលចាំបាច់ ។ ការរៀបចំនិងការប្រព្រឹត្តិទៅនៃព្រឹទ្ធសភានឹងមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា ។ បទបញ្ជាផ្ទៃក្នុងនេះ ត្រូវអនុម័តយល់ព្រមដោយសំឡេងភាគច្រើន ពីរភាគបីនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

**មាត្រា ១១៥ .–ថ្មី**

ក្នុងករណីមានសមាជិកព្រឹទ្ធសភាទទួលអនិច្ចកម្ម លាលែងឬប្រាសចាកសមាជិកភាពដែលកើតមានឡើងប្រាំមួយខែយ៉ាងតិចមុនចប់នីតិកាល ត្រូវចាត់តាំងឬជ្រើសតាំងជំនួសសមាជិកនោះតាមល័ក្ខខ័ណ្ឌកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភានិងក្នុងច្បាប់ ស្តីពីការចាត់តាំងនិងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

## ជំពូកទី ៩ ថ្មី

## អំពី

# សមាជរដ្ឋសភា និងព្រឹទ្ធសភា

**មាត្រា ១១៦ .–ថ្មី**

ក្នុងករណីចាំបាច់ រដ្ឋសភា និង ព្រឹទ្ធសភាអាចប្រជុំរួមគ្នាជាសមាជ ដើម្បីដោះស្រាយបញ្ហាសំខាន់ៗរបស់ប្រទេសជាតិ ។

**មាត្រា ១១៧ .-ថ្មី**

បញ្ហាសំខាន់ៗរបស់ប្រទេសជាតិដូចមានចែងក្នុងមាត្រា ១១៦ថ្មី ខាងលើ ព្រមទាំងការរៀបចំ និងការប្រព្រឹត្តិទៅនៃសមាជ នឹងត្រូវកំណត់ក្នុងច្បាប់មួយ ។

## ជំពូកទី ១០ ថ្មី
## អំពី
# រាជរដ្ឋាភិបាល

**មាត្រា ១១៨ .-ថ្មី (មាត្រា ៩៩ ចាស់)**

គណៈរដ្ឋមន្ត្រីជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

គណៈរដ្ឋមន្ត្រីត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប អមដោយឧបនាយករដ្ឋមន្ត្រី ព្រមទាំងមានទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាសមាជិក ។

**មាត្រា ១១៩ .-ថ្មី (មាត្រា ១០០ ចាស់)**

តាមសេចក្តីស្នើពីប្រធាន ដោយមានមតិឯកភាពពីអនុប្រធានទាំងពីរនៃរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូប ក្នុងចំណោមតំណាងរាស្ត្រនៃគណបក្សដែលឈ្នះឆ្នោត អោយបង្កើតរាជរដ្ឋាភិបាល ។ វរជនដែលត្រូវបានចាត់តាំងនេះ នាំសហការីដែលជាតំណាងរាស្ត្រ ឬជាសមាជិកគណបក្សតំណាងនៅក្នុងរដ្ឋសភា ដែលស្នើផ្តល់អោយកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល ទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភា ។ កាលបើរដ្ឋសភាបានបោះឆ្នោតទុកចិត្តហើយនោះ ព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យ តែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល ។

មុនចូលកាន់តំណែង គណៈរដ្ឋមន្ត្រីត្រូវធ្វើសច្ចាប្រណិធាន ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធ ៦ ។

**មាត្រា ១២០ .-ថ្មី (មាត្រា ១០១ ចាស់)**

មុខងារនៃសមាជិករាជរដ្ឋាភិបាល មានវិសមិតភាពនិងសកម្មភាពខាងវិជ្ជាជីវៈផ្នែកពាណិជ្ជកម្ម ឬ ឧស្សាហកម្ម ហើយនិងការកាន់តំណែងណាមួយក្នុងមុខងារសាធារណៈ ។

**មាត្រា ១២១ .-ថ្មី (មាត្រា ១០២ ចាស់)**

សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលទទួលខុសត្រូវរួមគ្នាចំពោះរដ្ឋសភា អំពីនយោបាយទូទៅ របស់រាជរដ្ឋាភិបាល ។

សមាជិកម្នាក់ៗនៃរាជរដ្ឋាភិបាលទទួលខុសត្រូវរៀងខ្លួន ចំពោះនាយករដ្ឋមន្ត្រី និងចំពោះរដ្ឋសភាអំពីការដែលខ្លួនបានប្រព្រឹត្ត ។

មាត្រា ១២២ .-ថ្មី (មាត្រា ១០៣ ចាស់)

សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលមិនអាចយកសំអាងនៃសេចក្តីបង្គាប់ដោយលាយលក្ខអក្សរ ឬ ដោយវាចាអំពីនរណាម្នាក់ ដើម្បីដោះសារអោយរួចខ្លួនពីការទទួលខុសត្រូវរបស់ខ្លួនបានឡើយ ។

មាត្រា ១២៣ .-ថ្មី (មាត្រា ១០៤ ចាស់)

គណៈរដ្ឋមន្ត្រីត្រូវប្រជុំរាល់សប្តាហ៍ ជាប្រជុំធំ ឬជាប្រជុំពិនិត្យស្រាវជ្រាវ ។

អង្គប្រជុំធំត្រូវដឹកនាំដោយនាយករដ្ឋមន្ត្រី ។ នាយករដ្ឋមន្ត្រីអាចប្រគល់ភារកិច្ចជូនឧបនាយករដ្ឋមន្ត្រីដឹកនាំអង្គប្រជុំពិនិត្យស្រាវជ្រាវបាន ។

កំណត់ហេតុនៃអង្គប្រជុំទាំងអស់របស់គណៈរដ្ឋមន្ត្រី ត្រូវធ្វើថ្វាយព្រះមហាក្សត្រទ្រង់ជ្រាប ។

មាត្រា ១២៤ .-ថ្មី (មាត្រា ១០៥ ចាស់)

នាយករដ្ឋមន្ត្រីអាចផ្ទេរអំណាចរបស់ខ្លួនអោយទៅឧបនាយករដ្ឋមន្ត្រី ឬសមាជិកណាមួយនៃរាជរដ្ឋាភិបាលបាន ។

មាត្រា ១២៥ .-ថ្មី (មាត្រា ១០៦ ចាស់)

បើតំណែងនាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរនោះ ត្រូវតែងតាំងគណៈរដ្ឋមន្ត្រីមួយជាថ្មី ក្នុងលក្ខខណ្ឌដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ ។ បើការទំនេរនេះជាការទំនេរមួយរយៈពេលមួយគ្រាទេ ត្រូវចាត់តាំងនាយករដ្ឋមន្ត្រីស្តីទីជាបណ្តោះអាសន្ន ។

មាត្រា ១២៦ .-ថ្មី (មាត្រា ១០៧ ចាស់)

សមាជិកម្នាក់ៗនៃរាជរដ្ឋាភិបាលត្រូវទទួលទណ្ឌកម្មពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលខ្លួនបានប្រព្រឹត្តក្នុងការបំពេញការងាររបស់ខ្លួន ។

ក្នុងករណីនេះនិងក្នុងករណីធ្វើខុសជាទម្ងន់ ក្នុងការបំពេញការងាររបស់ខ្លួន រដ្ឋសភាអាចសំរេចប្តឹងទៅតុលាការមានសមត្ថកិច្ច ។

រដ្ឋសភាសំរេចក្នុងរឿងនេះ ដោយវិធីបោះឆ្នោតជាសំងាត់ តាមមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។

មាត្រា ១២៧ .-ថ្មី (មាត្រា ១០៨ ចាស់)

ការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី នឹងត្រូវកំណត់ក្នុងច្បាប់មួយ ។

## ជំពូកទី ១១ ថ្មី

## អំពី

## អំណាចតុលាការ

មាត្រា ១២៨ .-ថ្មី (មាត្រា ១០៩ ចាស់)

-អំណាចតុលាការ ជាអំណាចឯករាជ្យ ។

-អំណាចតុលាការធានារក្សាអនាគត និងការពារសិទ្ធិ សេរីភាពរបស់ប្រជាពលរដ្ឋ ។

-អំណាចតុលាការគ្របដណ្តប់លើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង ។

-អំណាចនេះត្រូវប្រគល់អោយតុលាការកំពូល និងសាលាជំរះក្តីគ្រប់ថ្នាក់ និងគ្រប់ជាន់ថ្នាក់ ។

មាត្រា ១២៩ .-ថ្មី (មាត្រា ១១០ ចាស់)

ការជំរះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធីនិងច្បាប់ជាធរមាន ។

មានតែចៅក្រមទេ ដែលមានសិទ្ធិជំរះក្តី ។ ចៅក្រមត្រូវបំពេញភារកិច្ចនេះដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងដោយអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន ។

មាត្រា ១៣០ .-ថ្មី (មាត្រា ១១១ ចាស់)

គ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិ ឬនីតិប្រតិបត្តិអាចទទួលអំណាចតុលាការអ្វីបានឡើយ ។

មាត្រា ១៣១ .-ថ្មី (មាត្រា ១១២ ចាស់)

មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា ។

មាត្រា ១៣២ .-ថ្មី (មាត្រា ១១៣ ចាស់)

ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ ។

មាត្រា ១៣៣ .-ថ្មី (មាត្រា ១១៤ ចាស់)

ចៅក្រមមិនអាចត្រូវគេដកពីមុខងារបានទេ ។ ប៉ុន្តែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សំរេចដាក់វិន័យលើចៅក្រមដែលបានប្រព្រឹត្តខុស ។

មាត្រា ១៣៤ .-ថ្មី (មាត្រា ១១៥ ចាស់)

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនឹងត្រូវបង្កើតដោយច្បាប់រៀបចំអង្គការមួយដែលនឹងកំណត់សមាសភាព និងមុខងារ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ស្ថិតក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ ។ ព្រះមហាក្សត្រ ព្រះអង្គទ្រង់អាចចាត់តាំងព្រះរាជតំណាងម្នាក់របស់ព្រះអង្គអោយធ្វើជាអធិបតី នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រមនេះ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រអំពីការតែងតាំងចៅក្រម និងព្រះរាជអាជ្ញាអមសាលាជំរះក្តីទាំងអស់ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងមុខងារដាក់វិន័យចំពោះចៅក្រម និងព្រះរាជអាជ្ញា ត្រូវប្រជុំក្រោមអធិបតីភាពនៃប្រធានតុលាការកំពូល ឬអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល អាស្រ័យដោយករណីទាក់ទងនឹងចៅក្រម ឬ ព្រះរាជអាជ្ញា ។

មាត្រា ១៣៥ .-ថ្មី (មាត្រា ១១៦ ចាស់)

លក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញានិងការរៀបចំអង្គការតុលាការនឹងត្រូវកំណត់ក្នុងច្បាប់ដោយឡែកពីគ្នា ។

# ជំពូកទី ១២ ថ្មី
# អំពី
# ក្រុមប្រឹក្សាធម្មនុញ្ញ

**មាត្រា ១៣៦ .-ថ្មី**

ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ។

ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យ និងសំរេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

**មាត្រា ១៣៧ .-ថ្មី ( មាត្រា ១១៨ ចាស់ )**

ក្រុមប្រឹក្សាធម្មនុញ្ញមានសមាជិកប្រាំបួនរូប ដែលទទួលអាណត្តិប្រាំបួនឆ្នាំ ។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួនមួយភាគបី ត្រូវផ្លាស់ថ្មីក្នុងរយៈពេលបីឆ្នាំម្តង បីឆ្នាំម្តង ។ សមាជិកបីរូបត្រូវតែងតាំងដោយព្រះមហាក្សត្រ បីរូបត្រូវជ្រើសតាំងដោយរដ្ឋសភា ហើយបីរូបទៀត ត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

ប្រធានត្រូវបានជ្រើសតាំងដោយសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ។ ប្រធានមានសំឡេងឧត្តមានុភាពក្នុងករណីបែកសំឡេងជាពីរស្មើគ្នា ។

**មាត្រា ១៣៨ .-ថ្មី ( មាត្រា ១១៩ ចាស់ )**

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញត្រូវជ្រើសរើសក្នុងចំណោមឥស្សរជនដែលមានសញ្ញាបត្រចាប់ពីឧត្តមសិក្សាទៅខាងច្បាប់ ខាងរដ្ឋបាល ខាងការទូតឬខាងសេដ្ឋកិច្ច ហើយមានពិសោធន៍ច្រើនក្នុងការងារ ។

**មាត្រា ១៣៩ .-ថ្មី**

មុខងារសមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានវិសមិតភាពនឹងមុខងារសមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា សមាជិករាជរដ្ឋាភិបាល ចៅក្រមក្នុងតំណែង ការកាន់តំណែងណាមួយក្នុងមុខងារសាធារណៈ ប្រធាន ឬអនុប្រធានគណបក្ស នយោបាយ ប្រធាន ឬ អនុប្រធានសហជីព ។

**មាត្រា ១៤០ .-ថ្មី**

ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា តំណាងរាស្ត្រ ចំនួនមួយភាគដប់ ប្រធានព្រឹទ្ធសភា ឬសមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន អាចបញ្ជូនច្បាប់ដែលរដ្ឋសភាបានអនុម័តទៅអោយក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងច្បាប់នោះត្រូវប្រកាសអោយប្រើ ។

បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុននឹងប្រកាសអោយប្រើ ។ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសំរេច

ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃយ៉ាងយូរ ថាតើច្បាប់ បទបញ្ញត្តិក្នុងរដ្ឋសភា និងបទបញ្ញត្តិក្នុងព្រឹទ្ធសភាខាងលើស្រប ឬមិនស្របនឹងរដ្ឋធម្មនុញ្ញ ។

មាត្រា ១៤១ .-ថ្មី

ក្រោយពីច្បាប់ណាមួយត្រូវបានប្រកាសអោយប្រើ ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន តំណាងរាស្ត្រចំនួនមួយភាគដប់ ឬតុលាការអាចសុំអោយក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់នោះ ។

ប្រជារាស្ត្រមានសិទ្ធិប្តឹងអំពីធម្មនុញ្ញភាពនៃច្បាប់បាន តាមរយៈតំណាងរាស្ត្រ ឬ ប្រធានរដ្ឋសភា ឬសមាជិកព្រឹទ្ធសភា ឬប្រធានព្រឹទ្ធសភា ដូចមានចែងក្នុងវាក្យខណ្ឌខាងលើ ។

មាត្រា ១៤២ .-ថ្មី (មាត្រា ១២៣ ចាស់)

បទប្បញ្ញត្តិក្នុងមាត្រាណាដែលក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាមិនស្របនឹងរដ្ឋធម្មនុញ្ញ មិនអាចយកទៅប្រកាសអោយប្រើ ឬយកទៅអនុវត្តបានឡើយ ។

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាសេចក្តីសំរេចបិទផ្លូវតវ៉ា ។

មាត្រា ១៤៣ .-ថ្មី (មាត្រា ១២៤ ចាស់)

ព្រះមហាក្សត្រទ្រង់ពីគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញ ចំពោះសេចក្តីស្នើទាំងឡាយ ដែលសុំធ្វើវិសោធនកម្ម លើរដ្ឋធម្មនុញ្ញ ។

មាត្រា ១៤៤ .-ថ្មី (មាត្រា ១២៥ ចាស់)

ច្បាប់រៀបចំអង្គការមួយនឹងកំណត់ការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។

## ជំពូកទី ១៣ ថ្មី

## អំពី

# ការគ្រប់គ្រងរដ្ឋបាល

មាត្រា ១៤៥ .-ថ្មី (មាត្រា ១២៦ ចាស់)

ទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ចែកជាខេត្ត និង ក្រុង ។

ខេត្ត ចែកជាស្រុក ស្រុកចែកជា ឃុំ ។

ក្រុង ចែកជាខណ្ឌ ខណ្ឌចែកជាសង្កាត់ ។

មាត្រា ១៤៦ .-ថ្មី (មាត្រា ១២៧ ចាស់)

ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឃុំ និងសង្កាត់ ត្រូវគ្រប់គ្រងតាមពក្ខន័ណ្ឌដែលមានចែងក្នុងច្បាប់រៀបចំអង្គការមួយ ។

## ជំពូកទី ១៤ ថ្មី

## អំពី

## សមាជជាតិ

មាត្រា ១៤៧ .-ថ្មី (មាត្រា ១២៨ ចាស់)

សមាជជាតិបើកអោយប្រជារាស្ត្រជ្រាបដោយផ្ទាល់ អំពីកិច្ចការផ្សេងៗ ដែលជាប្រយោជន៍ជាតិ និងលើកបញ្ហា និងសំណូមពរ ជូនរដ្ឋអំណាចដោះស្រាយ ។

ប្រជារាស្ត្រខ្មែរទាំងពីរភេទ មានសិទ្ធិទៅចូលរួមក្នុងសមាជជាតិ ។

មាត្រា ១៤៨ .-ថ្មី (មាត្រា ១២៩ ចាស់)

សមាជជាតិប្រជុំមួយដងក្នុងមួយឆ្នាំ នៅដើមខែធ្នូ តាមការកោះអញ្ជើញរបស់នាយករដ្ឋមន្ត្រី។

សមាជជាតិប្រព្រឹត្តទៅក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ ។

មាត្រា ១៤៩ .-ថ្មី

សមាជជាតិអនុម័តសំណូមពរជូនព្រឹទ្ធសភា ជូនរដ្ឋសភា និងជូនរដ្ឋអំណាចពិចារណា ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជជាតិនឹងត្រូវកំណត់ក្នុងច្បាប់មួយ ។

## ជំពូកទី ១៥ ថ្មី

## អំពី

## អានុភាព ការសើរើ និង

## វិសោធនកម្មរដ្ឋធម្មនុញ្ញ

មាត្រា ១៥០ .-ថ្មី (មាត្រា ១៣១ ចាស់)

រដ្ឋធម្មនុញ្ញនេះជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា ។

ច្បាប់ និង សេចក្តីសម្រេចទាំងឡាយនៃស្ថាប័ននានា របស់រដ្ឋត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត ។

មាត្រា ១៥១ .-ថ្មី (មាត្រា ១៣២ ចាស់)

ការផ្តើមគំនិតសើរើឬការផ្តើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ជាសិទ្ធិរបស់ព្រះមហាក្សត្ររបស់នាយករដ្ឋមន្ត្រី និងរបស់ប្រធានរដ្ឋសភា តាមសេចក្តីស្នើរបស់តំណាងរាស្ត្រ មួយភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ការសើរើឬវិសោធនកម្មរដ្ឋធម្មនុញ្ញត្រូវធ្វើឡើងដោយច្បាប់ធម្មនុញ្ញមួយដែលអនុម័តដោយរដ្ឋសភាតាមមតិភាគច្រើនពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ១៥២ .-ថ្មី (មាត្រា ១៣៣ ចាស់)**

ការសើរើ ឬ វិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវបាមហាត់មិនអោយធ្វើ នៅពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ដូចមានចែងក្នុងមាត្រា ៨៦ ។

**មាត្រា ១៥៣ .-ថ្មី (មាត្រា ១៣៤ ចាស់)**

ការសើរើ ឬ វិសោធនកម្មរដ្ឋធម្មនុញ្ញមិនអាចធ្វើបានឡើយ កាលបើប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស និងរបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ ។

## ជំពូកទី ១៦ ថ្មី

## អំពី

## អន្តរប្បញ្ញត្តិ

**មាត្រា ១៥៤ .-ថ្មី**

រដ្ឋធម្មនុញ្ញនេះ ក្រោយពីបានទទួលការអនុម័ត ត្រូវបានប្រកាសអោយចូលជាធរមានភ្លាមដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១៥៥ .-ថ្មី (មាត្រា ១៣៦ ចាស់ )**

ក្រោយពេលរដ្ឋធម្មនុញ្ញនេះចូលជាធរមាន សភាធម្មនុញ្ញត្រូវក្លាយទៅជារដ្ឋសភា ។

បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាត្រូវចូលជាធរមាន ក្រោយទទួលបានការអនុម័តពីរដ្ឋសភា ។

ក្នុងករណីដែលរដ្ឋសភាមិនទាន់ចាប់ដំណើរការបាន ប្រធាន អនុប្រធានទីមួយ និងអនុប្រធានទីពីរនៃសភាធម្មនុញ្ញ នឹងចូលរួមបំពេញភារកិច្ចក្នុងក្រុមប្រឹក្សារាជសម្បត្តិបើសភាពការណ៍ក្នុងប្រទេសទាមទារ ។

**មាត្រា ១៥៦ .-ថ្មី**

ក្រោយរដ្ឋធម្មនុញ្ញនេះចូលជាធរមាន ព្រះមហាក្សត្រជ្រើសតាំងតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ១៣ថ្មី និង ១៤ ។

**មាត្រា ១៥៧ .-ថ្មី**

នីតិកាលទី១ នៃព្រឹទ្ធសភាមានកំណត់៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលព្រឹទ្ធសភាថ្មីចូលកាន់តំណែង ។

សំរាប់នីតិកាលទី១ នៃព្រឹទ្ធសភា :

-សមាជិកព្រឹទ្ធសភា មានចំនួនសរុប ហុកសិបមួយរូប ។

-ព្រះមហាក្សត្រទ្រង់តែងតាំងសមាជិកព្រឹទ្ធសភាពីររូប ព្រមទាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា ។

-សមាជិកដទៃទៀតនៃព្រឹទ្ធសភាត្រូវបានតែងតាំងដោយព្រះមហាក្សត្រ តាមសំណើរបស់ព្រឹទ្ធសភា និងប្រធានរដ្ឋសភា ក្នុងចំណោមសមាជិកនៃគណបក្សដែលមានអាសនៈនៅក្នុងរដ្ឋសភា ។

-កិច្ចប្រជុំជាសមាជិករដ្ឋសភា និងព្រឹទ្ធសភា ត្រូវដឹកនាំដោយសហប្រធាន ។

**មាត្រា ១៥៨ .-ថ្មី ( មាត្រា ១៣៩ ចាស់ )**

ច្បាប់ និងលិខិតបទដ្ឋានទាំងអស់នៅកម្ពុជា ដែលធានាការពារបាននូវទ្រព្យសម្បត្តិរដ្ឋ សិទ្ធិសេរីភាព និងទ្រព្យសម្បត្តិត្រឹមត្រូវតាមច្បាប់របស់បុគ្គលនិងដែលសមស្របនឹងប្រយោជន៍ជាតិត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀត រហូតដល់មានអត្ថបទថ្មីមកកែប្រែ ឬលុបចោល លើកលែងតែបទប្បញ្ញត្តិណាដែលផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញនេះ ។

ច្បាប់ធម្មនុញ្ញនេះ ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី ៤ ខែ មីនា ឆ្នាំ ១៩៩៩ ក្នុងសម័យប្រជុំវិសាមញ្ញ នីតិកាលទី២ ។

ភ្នំពេញ, ថ្ងៃទី ៦ ខែ មីនា ឆ្នាំ ១៩៩៩

ប្រធានរដ្ឋសភា

ព្រះហស្តលេខា និងត្រា

**នរោត្តម រណឫទ្ធិ**

★★★

**ឧបសម្ព័ន្ធទី ៧**

# សច្ចាប្រណិធាន

## ទូលព្រះបង្គំ

## យើងខ្ញុំ

## ប្រធាន អនុប្រធាន និងសមាជិកព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

## សូមធ្វើសច្ចាប្រណិធាន

## នៅចំពោះព្រះភក្ត្រព្រះមហាក្សត្រ ព្រះភក្ត្រនៃសម្តេចព្រះសង្ឃរាជ

## និងទេវតារក្សាស្វេតច្ឆត្រ

## ដូចតទៅ :

-ក្នុងពេលប្រតិបត្តិការ តាមមុខតំណែងខ្លួន និងក្នុងការបំពេញបេសកកម្មដែលប្រជារាស្ត្រកម្ពុជាបានប្រគល់ជូនចំពោះទូលព្រះបង្គំយើងខ្ញុំគ្រប់រូប ទូលព្រះបង្គំយើងខ្ញុំសូមប្តេជ្ញាគោរពរដ្ឋធម្មនុញ្ញ បំពើជានិច្ច

ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគតនូវផលប្រយោជន៏របស់ប្រជារាស្ត្រ ប្រជាជាតិ និងមាតុភូមិកម្ពុជា ។ ទូលព្រះបង្គំយើងខ្ញុំ សូមសច្ចាថា មិនកេងប្រវ័ញ្ចនូវផលប្រយោជន៏ជាតិ សំរាប់ផ្ទាល់ខ្លួន ឬសំរាប់គ្រួសារឬសំរាប់បក្សពួក ឬសំរាប់ភាគីផ្សេងៗខ្លួនឡើយ ។

-ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាប្តូរផ្តាច់ហ៊ានបូជាជីវិត ដើម្បីការពារជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគតនូវ :

- ឯករាជ្យភាពទាំងស្រុងនៃមាតុភូមិកម្ពុជា
- អធិបតេយ្យភាពជាតិពេញបរិបូរណ៍
- បូរណភាពទឹកដីដ៏ត្រឹមត្រូវតាមច្បាប់ នៅក្នុងព្រំដែនដីគោក និងព្រំដែនសមុទ្រ ដែលកម្ពុជាធ្លាប់មានក្នុងជំនាន់ ឆ្នាំ ១៩៦៣ ដល់ ១៩៦៩
- ឯកភាពជាតិ ហើយមិនអនុញ្ញាតអោយមានការបែងចែក ឬការធ្វើអបគមន៍ណាមួយឡើយ ។

-ទូលបង្គំយើងខ្ញុំ សូមប្តេជ្ញារក្សាទុកជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគតនូវអព្យាក្រឹត្យភាព និងភាពមិនចូលបក្សសម្ព័ន្ធសំរាប់កម្ពុជា ហើយមិនអនុញ្ញាតជាដាច់ខាតអោយជនណាមួយក៏ដោយ ដែលចង់ជ្រៀតជ្រែកចូលក្នុងផ្ទៃក្នុងនៃកម្ពុជា ឬមកបង្គាប់បញ្ជាចំពោះគោលនយោបាយជាតិ និងអន្តរជាតិរបស់កម្ពុជាបានឡើយ ។ ទូលព្រះបង្គំយើងខ្ញុំ មិនបំរើជាដាច់ខាតនូវផលប្រយោជន៏បរទេស ហើយធ្វើអោយខូចខាតដល់ផលប្រយោជន៏របស់ប្រជារាស្ត្រ ប្រជាជាតិ និងមាតុភូមិកម្ពុជាឡើយ ។

-ក្នុងការដោះស្រាយបញ្ហាទាំងឡាយលើផ្ទៃរាបជាតិ និងអន្តរជាតិ ទូលព្រះបង្គំយើងខ្ញុំនឹងបំបាត់ចោលទាំងស្រុងនូវអំពើហិង្សាគ្រប់បែបយ៉ាង ។

ប៉ុន្តែព្រះរាជាណាចក្រកម្ពុជា សូមរក្សាទុកនូវសិទ្ធិកាន់អាវុធតស៊ូប្រឆាំងនឹងការរំលោភឈ្លានពានមកពីក្រៅ ដើម្បីការពារជាតិមាតុភូមិខ្លួន ។

-ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាគោរពជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគតនូវលទ្ធិប្រជាធិបតេយ្យ សេរីនិយម ដែលមានរបបសភា និងពហុបក្ស ព្រមទាំងមានការគោរពយ៉ាងម៉ឺងម៉ាត់ចំពោះសិទ្ធិមនុស្ស ដូចមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស ។

-ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាតស៊ូប្រឆាំងអំពើពុករលួយគ្រប់បែបយ៉ាង ប្រឆាំងអយុត្តិធម៌សង្គម ហើយតស៊ូដើម្បីផ្សះផ្សាជាតិ ដើម្បីឯកភាពជាតិ ដើម្បីសន្តិភាពសង្គម និងសន្តិភាពជាតិ ដើម្បីភាពសម្បូរសប្បាយនៃប្រជារាស្ត្រកម្ពុជា និងដើម្បីភាពរុងរឿងថ្កើងថ្កាន នៃមាតុភូមិកម្ពុជា ជាទីគោរពសក្ការៈ និងជាទីស្នេហានៃទូលព្រះបង្គំយើងខ្ញុំគ្រប់រូប ។

★★★

# ២-ព្រះរាជក្រឹត្យ

## ព្រះរាជក្រឹត្យ នស/រកត/០៣៩៩/៣៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * * *

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១៦ ចុះថ្ងៃទី២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

### ត្រាស់បង្គាប់

មាត្រា ១ .- តែងតាំងឯកឧត្តម :

| | |
|---|---|
| ១-ឯកឧត្តម សឹុត ពេត | ជាទីប្រឹក្សារបស់ឯកឧត្តម តូល ឡោះ ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើនឹងអនុរដ្ឋលេខាធិការ ។ |
| ២-ឯកឧត្តម ញឹក វណ្ណារ៉ា | ឧបការីរបស់ឯកឧត្តម តូល ឡោះ ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើនឹងអគ្គនាយក ។ |
| ៣-លោកជំទាវ ស៊ូ សូមា | ឧបការីរបស់ឯកឧត្តម តូល ឡោះ ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើនឹងអគ្គនាយក ។ |
| ៤-ឯកឧត្តម សុខ សេងយ៉ន | ជាឧបការីរបស់ឯកឧត្តម តូល ឡោះ ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើនឹងអគ្គនាយក ។ |

មាត្រា ២ .- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ភ្នំពេញ,ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩

ព្រះហស្ថលេខា

នរោត្តម សីហនុ

★★★

**ព្រះរាជក្រឹត្យ នស/រកត/០៣៩៩/៣៨**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា**

**តែងតាំង**

**លោក ឈួន ហ៊ីង**

**ជា**

**ឧកញ៉ា**

ភ្នំពេញ , ថ្ងៃទី ០៤ ខែ មិនា ឆ្នាំ ១៩៩៩

ព្រះហស្ថលេខា

នរោត្តម សីហនុ

★★★

**ព្រះរាជក្រឹត្យ នស/រកត/០៣៩៩/៣៩**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជវរិវង្ស**

**ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

* * * *

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

ត្រាស់បង្គាប់

**មាត្រា ១ .-** តែងតាំងទីប្រឹក្សាក្រសួងមហាផ្ទៃដូចខាងក្រោម :

១-លោក **ចន ហូឡូវេ** (JOHN HOLLOWAY) ទទួលបន្ទុកកិច្ចការរដ្ឋបាល មានឋានៈស្មើអគ្គនាយក ។

២-លោក **គ្រីសចង់ ប៉ូលហ្គូត** (CHRISTIAN P,GUTH) ទទួលបន្ទុកកិច្ចការអន្តរជាតិ មានឋានៈស្មើអគ្គនាយក ។

**មាត្រា ២ .-** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ១៩៩៩

ព្រះហស្ថលេខា

**នរោត្តម សីហនុ**

***

## ព្រះរាជក្រឹត្យ នស/រកត/០៣៩៩/៤០

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស**

**ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨

-បានទ្រង់យល់ ព្រះរាជក្រម ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឮសេចក្តីស្នើរបស់នាយករដ្ឋមន្ត្រី

ត្រាស់បង្គាប់

**មាត្រា ១ .-** តែងតាំងឯកឧត្តម **មាសកេត្ត កែមរិន** ជាទីប្រឹក្សាអមក្រសួងសាធារណការ និងដឹកជញ្ជូនមានឋានៈ ស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា ២ .-** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ១៩៩៩

ព្រះហស្ថលេខា

**នរោត្តម សីហនុ**

★★★

**ព្រះរាជក្រឹត្យ នស/រកត/០៣៩៩/៤១**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា**

**តែងតាំង**

**ស្តេចក្រុមឃុន នរោត្តម សិរីវុឌ្ឍ**

**ជា**

**ឧត្តមប្រឹក្សាផ្ទាល់ របស់ព្រះមហាក្សត្រ**

**នៃ**

**ព្រះរាជាណាចក្រកម្ពុជា**

ភ្នំពេញ , ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ១៩៩៩

ព្រះហស្ថលេខា

**នរោត្តម សីហនុ**

★★★

## II- រាជរដ្ឋាភិបាល

## អនុក្រឹត្យ

### អនុក្រឹត្យ លេខ ៥០ អនក្រ.គត

### ស្តីពី

### ការជូនមេដាយស្ថាបនាជាតិ

* * *

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញ ព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តកំពត

### សំរេច

**មាត្រា ១ .-** ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **គុយ មូតា** សប្បុរសជន ជនជាតិជប៉ុន ដែលបានធ្វើអំណោយអាគារសិក្សា ០២ខ្នង មាន២០បន្ទប់ ជូនស្រុកកំពត ខេត្តកំពត និងអាគារសិក្សា០១ខ្នង មាន ១០បន្ទប់ ជូនក្រុងប៉ៃលិន រួមទាំងសំភារៈបរិក្ខារគ្រប់គ្រាន់ មានតម្លៃ សរុប ចំនួន ១៦១.២០០ ដុល្លារអាមេរិក ។

**មាត្រា ២ .-** ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្ត កំពត ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

# អនុក្រឹត្យ លេខ ៥១ អនក្រ.តត
## ស្តីពី
## ការជូនមេដាយស្ថាបនាជាតិ

* * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញ ព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តកំពត

## សំរេច

**មាត្រា ១ .-** ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកតា **កេយ៉ារ៉ុ មីយ៉ាម៉ា** សប្បុរសជនជនជាតិជប៉ុន ដែលបានធ្វើអំណោយអាគារសិក្សា ០២ខ្នង មាន១២បន្ទប់ ជូនស្រុកកំពត ខេត្តកំពត ដោយមានបំពាក់ទាំងសំភារៈបរិក្ខារគ្រប់គ្រាន់ មានតម្លៃសរុប ចំនួន ៧៩.៨០០ ដុល្លារអាមេរិក ។

**មាត្រា ២ .-** ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

***

# អនុក្រឹត្យ លេខ ៥២ អនក្រ.តត
## ស្ដីពី
## ការជូនមេដាយស្ថាបនាជាតិ

* * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញ ព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តកំពង់ឆ្នាំង

## សំរេច

**មាត្រា ១ .-** ត្រូវបានប្រគល់ **មេដាយស្ថាបនាជាតិ** ប្រគេននិងជូនសប្បុរសជន ដែលបានជួយកសាងអាគារសិក្សានៅក្នុងខេត្តកំពង់ឆ្នាំង ដូចមានរាយព្រះនាម និងនាមខាងក្រោមនេះ ៖

**ក-មេដាយមាសស្ថាបនាជាតិ :**

១-**ព្រះតេជគុណ អ៊ិន ឃឹម** កសាងអាគារសិក្សាមួយខ្នង នៅភូមិក្រាំងល្វា ឃុំក្រាំងល្វា ស្រុកសាមគ្គីមានជ័យ អស់ទឹកប្រាក់ ២៥.១៣០ USD ។

២-អ្នកស្រី INU ARYAL ប្រធានកម្មវិធីអង្គការ LWS កសាងអាគារសិក្សាមួយខ្នង នៅសាលាបឋមសិក្សាមានោក បរិត្យេងខ្ពស់ ស្រុកសាមគ្គី មានជ័យ អស់ទឹកប្រាក់ ២០.០៥០ USD ។

៣-លោក **នឹម ឈុន** អ្នកស្រី **នាយ គង់** កសាងអាគារសិក្សាមួយខ្នង នៅភូមិពោធិ៍អណ្តែត ឃុំកំពង់ហៅ ស្រុកកំពង់លែង អស់ទឹកប្រាក់ ១៩.៩៩៣ USD ។

**ខ-មេដាយសរិទ្ធ ស្ថាបនាជាតិ :**

១-លោក **ហុង តុង** អ្នកស្រី **តាំង គ្រួយ** ចូលរួមកសាងអាគារសិក្សា នៅភូមិក្រាំងល្វា ឃុំក្រាំងល្វា ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ទឹកប្រាក់ ២.៥០០ USD ។

មាត្រា ២ .- ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

**អនុក្រឹត្យ លេខ ៥៣ អនក្រ.តត**

**ស្តីពី**

**ការជូនមេដាយស្ថាបនាជាតិ**

* * *

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**សម្រេច**

មាត្រា ១ .- ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក Hector LOONTJENS ប្រធានមូលនិធិ SAWATDEE ដែលបានជួយកសាងអាគារបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន ០៦អាគារ និងបំពាក់

សំភារៈផលិតរាវពាងបាល់ទាត់ បាល់ទះ បាល់បោះ នៅក្រុងព្រះសីហនុ អស់ទឹកប្រាក់សរុប ចំនួន ១.៥០០.០០០ ដុល្លារអាមេរិក ។

មាត្រា ២ .- ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា និងអភិបាលក្រុងព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ។

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

**អនុក្រឹត្យ លេខ ៥៤ អនក្រ.តត**

**ស្តីពី**

**ការជូនមេដាយស្ថាបនាជាតិ**

***

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

**សំរេច**

មាត្រា ១ .- ត្រូវបានប្រគល់ **មេដាយប្រាក់** ស្ថាបនាជាតិជូនលោក **បាន ឡឿន** និង អ្នកស្រី **អ៊ិច រ៉ែ** ប្រធានគណៈកម្មការសប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក ដែលបានជួយឧបត្ថម្ភដល់មន្ទីរពេទ្យ ខេត្តបន្ទាយមានជ័យ នូវសំភារៈបរិក្ខារ មានតម្លៃជាទឹកប្រាក់ ចំនួន ៩.៥៩០ ដុល្លារអាមេរិក ។

**មាត្រា ២ .-** ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសុខាភិបាល និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

# អនុក្រឹត្យ លេខ ៥៥ អនក្រ.គត

## ស្តីពី

## ការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តតាកែវ

## សំរេច

**មាត្រា ១ .-** ត្រូវបានប្រគល់ **មេដាយមាស** ស្ថាបនាជាតិជូនសប្បុរសជន ដែលបានផ្តល់ថវិកា ចំនួន ៤២.២៤២ ដុល្លារអាមេរិក សំរាប់កសាងអាគារ០២ខ្នង នៅសាលាបឋមសិក្សា ស្រីសិត ក្នុងឃុំខ្វាវ ស្រុកទ្រាំង ខេត្តតាកែវ ដូចមានរាយនាមខាងក្រោម ៖

១-ស្ថានឯកអគ្គរាជទូតជប៉ុន ប្រចាំក្រុងភ្នំពេញ

២-លោកប្រធាន សហគមន៍ អាស៊ី-ខ្មែរ

**មាត្រា ២ .-** ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

# អនុក្រឹត្យ លេខ ៥៦ អនក្រ.តត

## ស្តីពី

## ការជូនមេដាយស្ថាបនាជាតិ

* * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៥

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី ក្រសួងអភិវឌ្ឍន៍ជនបទ

## សំរេច

| ១៥៧ | ម៉ិ | ចាន់មុនី | ប | ៣០-០១-៥៣ | |
| ១៥៨ | ម៉ិ | សំបាត | ប | ២២-០១-៧១ | |
| ១៥៩ | ម៉ិល | វណ្ណា | ស | ០១-០១-៥៧ | |

| | | | | | |
|---|---|---|---|---|---|
| ១៦០ | អ៊ុំ | ឆែម | ប | ១០-៥-៧០ | |
| ១៦១ | នាង | ភាព | ប | ០៥-៧-៧២ | |
| ១៦២ | ណាន | សុភ័ក្រ្ត | ស | ១២-៨-៥៦ | |
| ១៦៣ | នី | វណ្ណៈ | ស | ០៥-៤-៥៩ | |
| ១៦៤ | ណុប | បោងឡាយ | ប | ២៣-១០-៥៥ | |
| ១៦៥ | នួន | ស៊ីណោ | ប | ១៣-០១-៥៣ | |
| ១៦៦ | នួន | សុគន្ធ | ប | ០១-០១-៥៨ | |
| ១៦៧ | នួន | វុទ្ធី | ប | ០៤-៤-៦១ | |
| ១៦៨ | ផាន់ | បុប្ផា | ស | ១៥-០១-៥៩ | |
| ១៦៩ | ផន | ជីត | ប | ០៥-៨-៥៦ | |
| ១៧០ | ភុំ | ភីរូ | ប | ២៧-១២-៥៧ | |
| ១៧១ | ភីម | ភន | ប | ០៥-០២-៥៤ | |
| ១៧២ | ឈាង | ឆៃហ៊ាង | ប | ២៥-១២-៦៧ | |
| ១៧៣ | ធាយ | ណារី | ស | ១៥-៣-៦២ | |
| ១៧៤ | ធាយ | ស៊ីវអៀង | ស | ០១-០១-៥៨ | |
| ១៧៥ | ឈិន | សុផាន្នី | ស | ០១-០១-៥២ | |
| ១៧៦ | ធុំម | ស៊ីម៉ដ្ឋា | ស | ២៧-០១-៥៧ | |
| ១៧៧ | ឈន | ស៊ុណាត | ប | ០១-០១-៦៩ | |
| ១៧៨ | ឈូក | គីមឈាន | ប | ១៧-៩-៥១ | |
| ១៧៩ | ឈុន | ស៊ីណាត | ស | ០១-០៦-៦០ | |
| ១៨០ | ធីង | កូឡេ | ស | ១០-០២-៥៣ | |
| ១៨១ | ឈឹម | អុន្នី | ស | ០១-០១-៦៩ | |
| ១៨២ | ឈួន | សុធី | ប | ០១-០១-៥២ | |
| ១៨៣ | ប្រាក់ | ថាវ | ប | ០១-០១-៦០ | |
| ១៨៤ | ប្រាក់ | សុមារី | ស | ២០-១០-៥៨ | |
| ១៨៥ | ព្រហ្ម | សូផាត | ប | ១៥-០១-៥៥ | |
| ១៨៦ | ព្រឹង | សារឿន | ប | ០៣-៣-៥៦ | |
| ១៨៧ | ប្រឹង | សុវណ្ណ | ប | ០៧-០១-៦០ | |

| | | | | |
|---|---|---|---|---|
| ១៨៨ | ជ្រួយ ណឹមហ៊ុច | ប | ០១-០១-៦៣ | |
| ១៨៩ | ព្រួច ចាន់ថន | ស | ០៥-៧-៦៩ | |
| ១៩០ | រស់ សាវឿន | ប | ០១-០១-៦៧ | |
| ១៩១ | ស្រី សុទ្ធីវុធ | ប | ០៧-៣-៥៣ | |
| ១៩២ | ស្រី សុខន | ប | ១៥-១២-៦៣ | |
| ១៩៣ | ស៊ុំ យិមសឿន | ប | ២១-១០-៤៣ | |
| ១៩៤ | ស៊ុច សាមឿន | ស | ០១-០១-៥៥ | |
| ១៩៥ | ស៊ុក សាម៉ីន | ប | ០៧-៩-៥៩ | |
| ១៩៦ | ស៊ួន ម៉ារីយ៉ាន | ស | ២០-០២-៦៥ | |
| ១៩៧ | សាន ធន្នី | ស | ១៩-១០-៥៨ | |
| ១៩៨ | សាន ហ៊ុន | ប | ០២-៩-៥៨ | |
| ១៩៩ | សារិន សច្ចរ៉ា | ស | ៣១-១២-៧០ | |
| ២០០ | សាយ ពីដោរ | ប | ១៦-៤-៦៨ | |
| ២០១ | ស៊ិន គឹមឡូ | ប | ០១-០១-៥៨ | |
| ២០២ | សំ សុវណ្ណ | ប | ១៥-៥-៥៥ | |
| ២០៣ | សារិត ស្រ៊ន | ប | ០១-០១-៥៦ | |
| ២០៤ | សរ រស់ | ប | ០១-៤-៥៨ | |
| ២០៥ | សរ សំណាង | ប | ០១-០១-៦៨ | |
| ២០៦ | ស៊ូ សុសៃ | ប | ០៥-៩-៥៥ | |
| ២០៧ | ស៊ុក សុភី | ស | ០៩-១០-៦២ | |
| ២០៨ | ស៊ុន ធីតា | ស | ០៤-៣-៥៦ | |
| ២០៩ | ស៊ិន មុំ | ស | ២០-៦-៦៦ | |
| ២១០ | ស៊ិន ផាន់ណា | ស | ២៥-១១-៦៤ | |
| ២១១ | សុក កាន់ណារិទ្ធ | ប | ០១-០១-៦៧ | |
| ២១២ | សុក សារ៉ាន់ | ប | ១៥-១០-៥៣ | |
| ២១៣ | សុក សុន | ប | ០១-០១-៥៩ | |
| ២១៤ | សុន វាសនា | ប | ០១-០១-៥៩ | |
| ២១៥ | សួរ សុវណ្ណារី | ប | ១៥-០១-៥៤ | |

| | | | | | |
|---|---|---|---|---|---|
| ២១៦ | សុខ | ឡឿន | ប | ០១-០១-៥៧ | |
| ២១៧ | សុខ | កុសល | ប | ១៥-១២-៥៣ | |
| ២១៨ | សុខ | រី | ស | ០១-០១-៦៩ | |
| ២១៩ | សុខ | សុផា | ស | ០៦-៣-៥២ | |
| ២២០ | សុខ | រី | ស | ០១-០១-៥៥ | |
| ២២១ | សុខ | វន្នី | ស | ០១-០១-៦៥ | |
| ២២២ | ស៊ីង | កញ្ញារី | ស | ១៨-៩-៥៨ | |
| ២២៣ | ស៊ីម | សារុន | ប | ០១-០១-៥៥ | |
| ២២៤ | សួន | សេរី | ប | ០៥-១០-៥៩ | |
| ២២៥ | តាល់ | ហ៊ុច | ស | ០១-៤-៥៣ | |
| ២២៦ | តាល់ | វុត្ថា | ប | ០៥-៤-៥៨ | |
| ២២៧ | តាំង | តារា | ប | ០១-០១-៥២ | |
| ២២៨ | តាន់ | ប៊ុនថា | ស | ០៣-៦-៥៦ | |
| ២២៩ | តាន់ | សៀប | ប | ១៦-១០-៥០ | |
| ២៣០ | ទិត | ធី | ប | ០១-០១-៦៨ | |
| ២៣១ | ទិត | ភិន | ប | ០១-០១-៦២ | |
| ២៣២ | ទន់ | ឯន់ | ប | ០១-០១-៥១ | |
| ២៣៣ | តុប | ទៀង | ប | ០១-០១-៥០ | |
| ២៣៤ | តុប | ណាត | ប | ០១-០១-៥៩ | |
| ២៣៥ | តូច | ឡឿន | ប | ០១-០១-៦៥ | |
| ២៣៦ | ទូច | ស្រីណាក់ | ស | ០៣-៥-៦៩ | |
| ២៣៧ | ទូច | សារ៉ | ប | ១៧-១១-៥២ | |
| ២៣៨ | ទូច | វ៉ន | ប | ១០-០១-៥៣ | |
| ២៣៩ | ទូន | សោភ័ណ្ឌា | ប | ០១-០១-៦០ | |
| ២៤០ | ភ៊ន់ | សុខ | ប | ០១-០១-៥៧ | |
| ២៤១ | វង្ស | វុទ្ធី | ស | ១៥-៨-៥៩ | |
| ២៤២ | វួន | ចិណ្ណារ៉ា | ស | ១៧-៣-៥៦ | |
| ២៤៣ | បើន | ទិព្វមុនី | ប | ២៣-៦-៦៣ | |

| | | | | | |
|---|---|---|---|---|---|
| ២៤៤ | ឃិម | កាន់ណារ៉ា | ស | ០១-៩-៥២ | |
| ២៤៥ | យ៉ង | សាខន | ប | ០៧-១២-៦៦ | |
| ២៤៦ | យ៉ាវ | គីមសន | ប | ១២-០១-៥៧ | |
| ២៤៧ | យាំ | ស៊ីសុផល | ប | ១០-១០-៥៨ | |
| ២៤៨ | យង់ | ចន្ថា | ប | ២០-០២-៦៦ | |
| ២៤៩ | យិន | ណារី | ស | ០១-០១-៥១ | |
| ២៥០ | យស់ | សេង | ប | ០១-០១-៥២ | |
| ២៥១ | យិម | សម្បត្តិ | ប | ១២-០២-៥៦ | |

បានបញ្ឈប់បញ្ជីនេះត្រឹមលេខរៀង ពីររយហាសិបមួយ "២៥១"

ភ្នំពេញ , ថ្ងៃទី ០២ ខែ មិនា ឆ្នាំ ១៩៩៩

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

អ៊ឹម ឈុនលឹម

★★★

## ៤-ឧិស្តីការរដ្ឋមន្ត្រី ក្រសួងអប់រំយុវជន និងកីឡា

## ១-ប្រកាស

ភ្នំពេញ , ថ្ងៃទី ០៤ ខែ មិនា ឆ្នាំ ១៩៩៩

### ប្រកាស លេខ ១៤៩ អយក.ប្រក

### ស្តីពី

### ការរៀបចំ និងការប្រព្រឹត្តិទៅ នៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ

*****

### រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.០៧៩៦/៥២ ចុះថ្ងៃទី២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីអំពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ ។

-បានឃើញលិខិតឧទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី លេខ ២២៣៧ សជណ.អវ ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩០ ស្តីពីការប្តូរឈ្មោះសាលារៀនចំណេះទូទៅ

-បានឃើញលិខិត របស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ ៩០៧ សជណ.អរ ចុះថ្ងៃទី១២ ខែឧសភា ១៩៩៥ ស្តីពីការអនុញ្ញាតជាគោលការណ៍អោយប្រលងសញ្ញាបត្រមធ្យមសិក្សាពីរលើក

-យោងតាមការចាំបាច់របស់ ក្រសួងអប់រំ យុវជន និងកីឡា ។

## សំរេច

ប្រការ ១ : មណ្ឌលប្រលងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ លើកទី១ និងលើកទី២ ត្រូវកំណត់ដោយក្រសួងអប់រំយុវជន និងកីឡា រៀងរាល់ឆ្នាំសិក្សា ។

ប្រការ ២ : ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុង និង នាយកគ្រឹះស្ថានសិក្សា ដែលគ្រឹះស្ថានត្រូវបានកំណត់ជាមណ្ឌលប្រលងមានភារៈរៀបចំបន្ទប់ប្រលង កំរងសលាកប័ត្រឯកត្តជនរបស់បេក្ខជន បញ្ជីផ្សេងៗ និងសំភារៈចាំបាច់សំរាប់ការប្រព្រឹត្តិទៅនៃការប្រលងអោយហើយស្រេច មុនបើកសម័យប្រលង ។

-ចំពោះសាលារៀនក្រោមឱវាទផ្ទាល់នៃក្រសួងអប់រំ យុវជន និងកីឡា នាយកគ្រឹះស្ថានសិក្សាក៏ត្រូវអនុវត្តដូចមណ្ឌលនានាដែរ តាមការណែនាំរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ។

ប្រការ ៣ : មណ្ឌលប្រលងនីមួយៗ ត្រូវមានប្រធាន អនុប្រធាន និងសមាជិកគណៈមេប្រយោគមួយចំនួនតាមការចាំបាច់នៃមណ្ឌលប្រលង ។

ប្រការ ៤ : សមាសភាព និងចំនួន ព្រមទាំងលិខិតឧទ្ទេសនាមគណៈមេប្រយោគ ត្រូវសំរេចដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា តាមសំណើរបស់ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ។

ប្រការ ៥ : ចំនួនអនុរក្ស នៃមណ្ឌលប្រលង ត្រូវគិតតាមចំនួនបន្ទប់ប្រលង គុណ នឹង ២,៥ ។

ប្រការ ៦ : បន្ទប់ប្រលងនីមួយៗត្រូវដាក់បេក្ខជនត្រឹម ២៥ "ម្ភៃប្រាំ " នាក់ ។ បើមានបេក្ខជននៅសល់ ០៥ "ប្រាំ" នាក់ឡើងទៅ ត្រូវដាក់ក្នុងបន្ទប់មួយដោយឡែក ។

ប្រការ ៧ : ប្រធានគណៈមេប្រយោគ នៃមណ្ឌលនីមួយៗ ជាអ្នកទទួលខុសត្រូវរួម ក្នុងដំណើរការប្រព្រឹត្តិទៅនៃការប្រលងទាំងផ្នែករដ្ឋបាល ទាំងផ្នែកបច្ចេកទេសចំពោះក្រសួងអប់រំ យុវជន និងកីឡា ។

ប្រការ ៨ : ប្រធានគណៈមេប្រយោគ ត្រូវសហការ ឬធ្វើអន្តរាគមន៏ដល់អាជ្ញាធរមានសមត្ថកិច្ចនានាក្នុងខេត្ត - ក្រុង នៃមណ្ឌលប្រលង ក្នុងករណីចាំបាច់ ដើម្បីរក្សារបៀបរៀបរយក្នុងពេលប្រលង ។

ប្រការ ៩ : មណ្ឌល ឬ អនុមណ្ឌលប្រលងណាមួយដែលមិនមានភាពប្រក្រតីតាមលក្ខការណ៍នៃការប្រលង ប្រធានគណៈមេប្រយោគនៃមណ្ឌល ឬ អនុមណ្ឌលនោះ ត្រូវរាយការណ៏ជាបន្ទាន់មកគណៈ

មេប្រយោគ ទូទាំងខេត្ត-និងអាជ្ញាធរដែនដី ដើម្បីដោះស្រាយ ឬសុំការសំរេចពីក្រសួងអប់រំ យុវជន និងកីឡា ។

ប្រការ ១០ : ប្រធានគណៈមេប្រយោគ ត្រូវបែងចែកភារកិច្ចដល់អនុប្រធាន និងសមាជិកគណៈមេប្រយោគ អោយទទួលខុសត្រូវតាមមុខងាររៀងៗខ្លួន ។

ប្រការ ១១ : ភារកិច្ចគណៈកម្មការ អនុគណៈកម្មការ និងសមាជិកនៃគណៈមេប្រយោគនឹងមានចែងក្នុងសេចក្តីណែនាំមួយរបស់ ក្រសួងអប់រំ យុវជន និងកីឡា ។

ប្រការ ១២ : នឹងអនុញ្ញាតអោយចុះឈ្មោះប្រលងលើកទី១បាន សិស្សថ្នាក់ទី៩ នៃគ្រឹះស្ថានមធ្យមសិក្សាសាធារណៈ និងឯកជនដែលបានរៀនចប់កម្មវិធីសិក្សាថ្នាក់ទី៩ និងគោរពបានត្រឹមត្រូវនូវបទបញ្ញាផ្ទៃក្នុងសំរាប់គ្រឹះស្ថានមធ្យមសិក្សា ហើយត្រូវបានវាយតម្លៃផ្នែកសីលធម៌ប្រចាំឆ្នាំ ចាប់ពីមធ្យមឡើងទៅ និង អតីតបេក្ខជនដែលបានប្រលងធ្លាក់សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ (បេក្ខជនស្វ័យរិន) ។ ពាក្យសុំចុះឈ្មោះប្រលងពានបិទតែម ត្រូវស្នើសុំទៅរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា តាមឋានានុក្រម ។

ប្រការ ១៣ : នឹងអនុញ្ញាតអោយចូលរួមប្រលងលើកទី២បាន ៖

-បេក្ខជនដែលប្រលងធ្លាក់លើកទី១ និងបានពិន្ទុប្រលងនៃការប្រលងសញ្ញាបត្រមធ្យមសិក្សា បឋមភូមិលើកទី១ ចាប់ពីពិន្ទុ ១៧៥ឡើងទៅ ។

-បេក្ខជនដែលបានដាក់ពាក្យសុំប្រលងលើកទី១ តែអាក់ខានពុំបានចូលរួមប្រលង ឬបានចូលរួមប្រលងពុំបានគ្រប់មុខវិជ្ជា ដោយមូលហេតុមានជំងឺ ឬគ្រោះថ្នាក់ផ្សេងៗជាក់ស្តែង ហើយមានពាក្យសុំច្បាប់ត្រឹមត្រូវដោយមានការបញ្ជាក់ពីឪពុកម្តាយ ឬអាណាព្យាបាល ស្នើសុំទៅរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា តាមរយៈប្រធានមណ្ឌល ដែលសាមីខ្លួនត្រូវប្រលង ។

-បេក្ខជនស្វ័យរិនដែលប្រលងធ្លាក់លើកទី១ និងបានពិន្ទុប្រលងថ្នាក់ជាតិលើកទី១ ចាប់ពីពិន្ទុ១៥០ឡើងទៅ ។

ប្រការ ១៤ : អាចសុំចុះឈ្មោះប្រលងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ជាបេក្ខជនស្វ័យរិនបាន អតីតបេក្ខជនដែលបានប្រលងធ្លាក់សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ ។

ប្រការ ១៥ : បេក្ខជន ត្រូវភ្ជាប់នឹងពាក្យសុំប្រលងរបស់ខ្លួននូវ ៖

- សលាកបត្រឯកត្តជនទំហំ ១៥ សម គុណនឹង២១ សម មានបិទរូបថតថ្មី ថតចំពីមុខ ទំហំ ៤ សម គុណនឹង ៦ សម ចំនួន ៥ សន្លឹក ។
- បង្កាន់ដៃបង់សិទ្ធិប្រលង ១ ច្បាប់
- រូបថត ថតថ្មី ថតចំពីមុខ ទំហំ ៤សម គុណនឹង ៦ សម " រូបថតដែលបានបិទលើសលាកប័ត្រឯកត្តជន " ចំនួន៣សន្លឹក ។

- សៀវភៅសិក្ខាគារិក " ចំពោះសិស្សសាលាឯកជន " ។

**ប្រការ ១៦** : ពាក្យសុំចុះឈ្មោះប្រលងលើកទី១ និងលើកទី២ នឹងត្រូវប្រមូលផ្ដុំតាមគ្រឹះស្ថានសិក្សា ដែលខ្លួនសិក្សា ។ នាយកគ្រឹះស្ថានសិក្សាត្រូវប្រមូលសំណុំលិខិតរបស់បេក្ខជនបញ្ជូនទៅមន្ទីរអប់រំ យុវជន

និង កីឡា ខេត្ត-ក្រុង ដើម្បីធ្វើការបែងចែកឈ្មោះបេក្ខជនតាមលំដាប់អក្សរក្រមទៅតាមបន្ទប់ ប្រលង ។

**ប្រការ ១៧** : បេក្ខជនដែលបានប្រកាសថា ត្រូវបានប្រលង លើកទី២ មិនបាច់ដាក់ពាក្យសុំប្រលងទៀតទេ ។ មន្ទីរអប់រំយុវជន នឹងកីឡា ខេត្ត-ក្រុង មានភារៈរៀបចំបែងចែកឈ្មោះបេក្ខជន តាមលំដាប់អក្សរក្រមទៅតាមបន្ទប់ប្រលង ។

**ប្រការ ១៨** : បេក្ខជនស្វ័យរិន ត្រូវដាក់ពាក្យសុំប្រលងលើកទី១ ដោយមានបញ្ជាក់សម័យប្រលង មណ្ឌលប្រលង លេខបន្ទប់ លេខតុ នៃសម័យប្រលងមុន នៅតាមមន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុង ដែលសាមីខ្លួនបានសុំប្រលងពីមុន ។ បើមានបំណងចង់ប្រលងនៅខេត្ត-ក្រុងថ្មីដែលខ្លួនបានប្ដូរលំនៅដ្ឋាននោះ ត្រូវមានសេចក្ដីបញ្ជាក់លើពាក្យសុំប្រលងពីមន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុង ដែលសាមីខ្លួនបានប្រលងធ្លាក់ពីមុន ។

**ប្រការ ១៩** : មន្ទីរអប់រំយុវជន និងកីឡា ខេត្ត-ក្រុង ត្រូវធ្វើបញ្ជីរាយនាមបេក្ខជន ផ្ញើទៅ ក្រសួងអប់រំ យុវជន និងកីឡា "នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ" ដើម្បីពិនិត្យ និងសំរេច លើបេក្ខភាព ។

**ប្រការ ២០** : បេក្ខជនត្រូវអនុវត្តតាមបទបញ្ញត្តិទូទៅនៃការប្រលង ដែលមានចែងក្នុងអត្ថបទមួយដោយឡែក ។

**ប្រការ ២១** : វិញ្ញាសា ថិរវេលា និងពិន្ទុនៃការប្រលង សញ្ញាបត្រ មធ្យមសិក្សាបឋមភូមិ លើកទី១ និង លើកទី២ ត្រូវបានកំណត់ដូចតទៅ ៖

១- ភាសាខ្មែរ រយៈពេល ១ម៉ោងកន្លះ ត្រូវបានពិន្ទុពី ០ ដល់១០០

២- គណិតវិទ្យា រយៈពេល ១ម៉ោង ត្រូវបានពិន្ទុពី ០ ដល់១០០

៣- វិទ្យាសាស្ត្រពិត រយៈពេល ១ម៉ោង ត្រូវបានពិន្ទុពី៖ ០ ដល់១០០

ក្នុងនោះមាន ៖

- រូបវិទ្យា និង គីមី រយៈពេល ៣០នាទី ត្រូវបានពិន្ទុពី ០ ដល់ ៥០
- ជីវវិទ្យា និង ផែនដីវិទ្យា រយៈពេល ៣០នាទី ត្រូវបានពិន្ទុពី ០ ដល់ ៥០

៤- វិទ្យាសាស្ត្រសង្គម រយៈពេល ១ម៉ោង ត្រូវបានពិន្ទុពី ០ ដល់១០០

ក្នុងនោះមាន ៖

- សីលធម៌ - ពលរដ្ឋវិជ្ជា រយៈពេល ៣០នាទី ត្រូវបានពិន្ទុពី ០ ដល់ ៥០
- ប្រវត្តិវិទ្យា និង ភូមិវិទ្យា រយៈពេល ៣០នាទី ត្រូវបានពិន្ទុពី ០ ដល់ ៥០

៥- ជីវភាសា (បារាំង ឬ អង់គ្លេស) រយៈពេល ៤៥ នាទី ត្រូវបានពិន្ទុពី ០ ដល់៥០

វិញ្ញាសានីមួយៗ នឹងត្រូវបានពិន្ទុ សូន្យចំពោះបេក្ខជនអវត្តមាន ឬ បេក្ខជនដែលមិនបាន ប្រគល់សន្លឹកកិច្ចការដល់គណៈមេប្រយោគ ។

ប្រការ ២២ : បេក្ខជនទាំងឡាយអាចជ្រើសរើស យកភាសាតែមួយប៉ុណ្ណោះក្នុងចំណោមភាសាបារាំង ឬ ភាសាអង់គ្លេស នៅពេលធ្វើវិញ្ញាសាជីវភាសា ។

ប្រការ ២៣ : ពិន្ទុជីវភាសានឹងគិតយកតែពិន្ទុ ដែលបេក្ខជនធ្វើបានលើសពី២៥ទៅបូកបញ្ចូលជាមួយពិន្ទុមុខវិជ្ជាផ្សេងៗទៀត ។

ប្រការ ២៤ : ប្រធានវិញ្ញាសាប្រលង ត្រូវយកតាមកម្មវិធីថ្នាក់ទី៩ នៃមធ្យមសិក្សាបឋមភូមិ ។ វិញ្ញាសាទាំងឡាយ ជាវិញ្ញាសាសរសេរទាំងអស់ ។

ប្រការ ២៥ : ប្រធានវិញ្ញាសាទាំងឡាយត្រូវជ្រើសរើស ឬ តាក់តែងដោយក្រសួងអប់រំ យុវជន និង កីឡា ។

ប្រការ ២៦ : ប្រធានវិញ្ញាសាទាំងឡាយ ដែលបានជ្រើសរើសរួចហើយត្រូវដាក់ក្នុងស្រោមសំងាត់បិទជិត និងប្រថាប់ត្រា ហើយត្រូវបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចដែលមានមណ្ឌលប្រលង តាមរយៈមេប្រយោគ ទូទាំងខេត្ត អោយថែរក្សាទុក៧២ម៉ោង មុនពេលប្រកាស ចាប់ផ្ដើមប្រលង ។

ប្រការ ២៧ : អាជ្ញាធរមានសមត្ថកិច្ច ដែលថែរក្សាវិញ្ញាសាទាំងនោះ ត្រូវប្រគល់អោយគណៈមេប្រយោគទូទាំងខេត្ត នៅថ្ងៃចាប់ផ្ដើមការប្រលងមួយម៉ោង មុនពេលបើកសម័យប្រលង ។

ប្រការ ២៨ : ការប្រគល់អោយ និងការទទួលយកវិញ នូវប្រធានវិញ្ញាសាប្រលងត្រូវមានការទទួលខុសត្រូវ ទាំងសងខាង ដោយមានកំណត់ហេតុជាផ្លូវការផង ។

ប្រការ ២៩ : វិញ្ញាសានីមួយៗ ត្រូវមានចំនួនសន្លឹកវិញ្ញាសា ស្មើនឹងចំនួនបេក្ខជន ។ បើខ្វះត្រូវចំលងបន្ថែមបង្គ្រប់ភ្លាម ។

ប្រការ ៣០ : វិញ្ញាសាសរសេរនីមួយៗ ត្រូវកែដោយសមាជិកកំរែពីរនាក់ជាដាច់ខាត តាមតារាងអត្រាកំណែ ដែលគណៈមេប្រយោគបានសំរេច ។

ប្រការ ៣១ : ពិន្ទុសរុបនៃពិន្ទុ គ្រប់វិញ្ញាសា ហៅថាពិន្ទុប្រលងថ្នាក់ជាតិ ជាពិន្ទុលើ ៥០០ ។

ប្រការ ៣២ : ពិន្ទុប្រចាំឆ្នាំ ស្មើនឹងមធ្យមភាគពិន្ទុប្រចាំឆមាសទី១ បូកនឹងមធ្យមភាគពិន្ទុប្រចាំឆមាសទី២ ជាពិន្ទុលើ ១០០ ។

ប្រការ ៣៣ : ពិន្ទុប្រលងស្មើនឹងពិន្ទុប្រចាំឆ្នាំ បូកនឹង ពិន្ទុប្រលងថ្នាក់ជាតិ ។

ប្រការ ៣៤ : នឹងត្រូវប្រកាសថា ប្រលងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ បេក្ខជនទាំងឡាយណា ដែលបានពិន្ទុប្រលងចាប់ពី ២៥០ឡើងទៅ និង បេក្ខជនស្វ័យរិន ទាំងឡាយណាដែលបានពិន្ទុប្រលងថ្នាក់ជាតិ ចាប់ពី២០០ឡើងទៅ ដោយឥតមានពិន្ទុសូន្យចំពោះវិញ្ញាសាណាមួយ លើកលែងតែវិញ្ញាសាជីវភាសា ។

ក្នុងករណីចាំបាច់ គណៈមេប្រយោគអាចធ្វើសំរង់អោយជាប់បន្ថែម ក្រោយពីមានការយល់ព្រមពីក្រសួងអប់រំ យុវជន និងកីឡា តាមភាពជាក់ស្តែង និងតាមសំណើរបស់គណៈមេប្រយោគ ។ បេក្ខជនស្វ័យរិនមិនធ្វើសំរង់អោយជាប់បន្ថែមឡើយ ។

ប្រការ ៣៥ : គណៈមេប្រយោគមណ្ឌលប្រលងនីមួយៗ ត្រូវប្រជុំពិភាក្សារួមដើម្បីសំរេចលទ្ធផល នៃការប្រលង ។ កំណត់ហេតុ និងបញ្ជីចាំបាច់នានាភ្ជាប់មកជាមួយ ត្រូវបញ្ជូនទៅក្រសួង អប់រំ យុវជន និងកីឡា ជាពីរច្បាប់ ដើម្បីសុំសេចក្តីយល់ព្រម ។

ប្រការ ៣៦ : និទ្ទេសត្រូវបានកំណត់តាមពិន្ទុប្រលងដូចតទៅ ៖

*ចំពោះបេក្ខជននៃគ្រឹះស្ថានមធ្យមសិក្សាសាធារណៈ និង ឯកជន :

| | | |
|---|---|---|
| ចាប់ពីពិន្ទុ ២៥០ | ទៅពិន្ទុ ៣២៤,៩៩ | និទ្ទេសមធ្យម |
| ចាប់ពីពិន្ទុ ៣២៥ | ទៅពិន្ទុ ៣៩៩,៩៩ | និទ្ទេសល្អបង្គួរ |
| ចាប់ពីពិន្ទុ ៤០០ | ឡើងទៅ | និទ្ទេសល្អ |

* ចំពោះបេក្ខជនស្វ័យរិន :

| | | |
|---|---|---|
| ចាប់ពីពិន្ទុ ២០០ | ទៅពិន្ទុ ២៥៩ | និទ្ទេសមធ្យម |
| ចាប់ពីពិន្ទុ ២៦០ | ទៅពិន្ទុ ៣១៩ | និទ្ទេសល្អបង្គួរ |
| ចាប់ពីពិន្ទុ ៣២០ | ឡើងទៅ | និទ្ទេសល្អ |

ប្រការ ៣៧ : នឹងត្រូវប្រកាសថាត្រូវបានប្រលងលើកទី២ បេក្ខជនទាំងឡាយណា ដែលមិនបានប្រកាសថាប្រលងជាប់លើកទី១ ហើយបានពិន្ទុប្រលងចាប់ពី១៧៥ ( ចំពោះបេក្ខជននៃគ្រឹះស្ថានមធ្យមសិក្សា សាធារណៈ និង ឯកជន ) និងបានពិន្ទុប្រលងថ្នាក់ជាតិ ចាប់ពី១៤០ឡើងទៅ (ចំពោះបេក្ខជនស្វ័យរិន) ដោយមិនគិតពិន្ទុសូន្យចំពោះមុខវិជ្ជាណាមួយឡើយ ។

ប្រការ ៣៨ : បទបញ្ញត្តិ ស្តីពីការរៀបចំប្រលងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិពីមុនៗទាំងឡាយណា ដែលផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៣៩ : អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកអប់រំ និងប្រធានអង្គភាពពាក់ព័ន្ធ នៃក្រសួងអប់រំយុវជន និងកីឡា ត្រូវអនុវត្តតាមភារកិច្ចរៀងៗខ្លួន ដើម្បីអោយបានសំរេចនូវប្រកាសនេះ ។

ហត្ថលេខានិងត្រា

តុល ឡោះ

★★★

## ២-សារាចរណែនាំ

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ១៩៩៩

### សារាចរណែនាំ លេខ ០១ អយក.សរណន

### ស្តីពី

### ការប្រឡងបញ្ចប់គ្រប់តួមិសិក្សាផ្នែកចំនេះទូទៅ

### បំពេញវិជ្ជាសាធារណៈ និង ឯកជន

* * * *

### រដ្ឋមន្ត្រី

- យោង : ប្រកាសលេខ ១៤៩ និងលេខ ១៥៣ អយក.ប្រក. របស់ក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី ០៤ និង០៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃការ ប្រលងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និង ទុតិយភូមិ
- សារាចរណែនាំអនុវត្ត លេខ ០៥ អយក/សរណន/ចទម របស់ក្រសួងអប់រំយុវជន និងកីឡា ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ១៩៩៦
- សេចក្តីណែនាំ លេខ ២៨៩១ អយក/ចទម ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការវាយតម្លៃរបស់សិស្សនៅមធ្យមសិក្សា របស់ក្រសួងអប់រំ យុវជន និងកីឡា

ចាប់ពីឆ្នាំសិក្សា ១៩៩៨-៩៩ នេះតទៅ ពិន្ទុប្រលងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិនិងទុតិយភូមិ ត្រូវយកពិន្ទុប្រចាំឆ្នាំ បូកនឹងពិន្ទុប្រលងថ្នាក់ជាតិ។

ដើម្បីអោយការរៀបចំប្រលងថ្នាក់ជាតិ និងការរៀបចំប្រលងតាមសាលារៀន មានលក្ខណៈល្អប្រសើរ ក្រសួងសូមធ្វើការណែនាំដូចតទៅ :

**I- កាលបរិច្ឆេទប្រលង :**

**I-1- ប្រលងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ :**

**I.1.1- ប្រលងលើកទី១**

- កាលបរិច្ឆេទនៃការប្រលង : ថ្ងៃទី ៩ ខែ សីហា ឆ្នាំ ១៩៩៩
- កាលបរិច្ឆេទនៃការទទួលពាក្យសុំប្រលង : ថ្ងៃទី២២ ខែ មេសា ១៩៩៩ ដល់ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៩៩

**I.1.2. ប្រលងលើកទី២**

- កាលបរិច្ឆេទនៃការប្រលង : ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៩៩ (បេក្ខជនពុំចាំបាច់ដាក់ពាក្យសុំប្រលងទៀតទេ)

I-2- ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ :

I.2.1- ប្រឡងលើកទី១

- កាលបរិច្ឆេទនៃការប្រឡង : ថ្ងៃទី ១៩ ខែ កក្កដា និង ព្រឹក ថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៩
- កាលបរិច្ឆេទនៃការទទួលពាក្យសុំប្រឡង : ថ្ងៃទី២២ ខែ មេសា ១៩៩៩ ដល់ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៩៩

I.2.2- ប្រឡងលើកទី២

- កាលបរិច្ឆេទនៃការប្រឡង : ថ្ងៃទី ៣០ ខែ សីហា និង ព្រឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩៩ ( បេក្ខជន ពុំចាំបាច់ដាក់ពាក្យសុំប្រឡងទៀតទេ )

II- បេក្ខភាពសិស្ស និងសំណុំលិខិតដាក់ពាក្យសុំប្រឡង :

II-1-សំណុំលិខិតដាក់ពាក្យសុំប្រឡងរបស់បេក្ខជន ត្រូវសរសេរដោយដៃបេក្ខជនផ្ទាល់ (គំរូជូនភ្ជាប់) បិទតែម ៣០០ ៛ និងមានភ្ជាប់បង្កាន់ដៃបង់សិទ្ធិប្រឡង ដូចខាងក្រោមៈ

- បេក្ខជនប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ បង់ថ្លៃសិទ្ធិប្រឡង ១០០០៛
- បេក្ខជនប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ បង់ថ្លៃសិទ្ធិប្រឡង ១៥០០៛

II-2- បេក្ខភាព :

* សិស្សសាលារៀនចំណេះទូទៅសាធារណៈ និងឯកជនដែលបានរៀនចប់កម្មវិធីថ្នាក់ទី៩ អាចដាក់ពាក្យសុំប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និងសិស្សដែលរៀនចប់កម្មវិធីថ្នាក់ទី១២ អាចដាក់ពាក្យសុំប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ នៅតាមគ្រឹះស្ថានសិក្សារបស់ខ្លួនបាន លើកលែងតែ :

- សិស្សដែលឈប់ដោយមានច្បាប់ ចាប់ពី ៤៥ ដងឡើងទៅ
- សិស្សដែលឈប់ឥតច្បាប់ និងមានច្បាប់ ចាប់ពី ៣០ ដងឡើងទៅ
- សិស្សដែលឈប់ឥតច្បាប់ ចាប់ពី ២០ ដងឡើងទៅ
- សិស្សដែលគ្មានមធ្យមភាគពិន្ទុប្រចាំឆមាសទី១ ឬ ឆមាសទី២
- សិស្សដែលទទួលការវាយតម្លៃខ្សោយ លើផ្នែកសីលធម៌រស់នៅ

* អតីតបេក្ខជនដែលបានប្រឡងធ្លាក់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ អាចដាក់ពាក្យសុំប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ នៅតាម មន្ទីរអប់រំយុវជន និងកីឡា ខេត្ត-ក្រុង ដែលសាមីខ្លួនបានសុំប្រឡងពីមុន ឬនៅនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នៃក្រសួងអប់រំយុវជន និងកីឡា ។

* អតីតបេក្ខជនដែលបានប្រលងធ្លាក់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ អាចដាក់ពាក្យសុំប្រលងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ នៅតាមមន្ទីរអប់រំយុវជន និងកីឡា ខេត្ត-ក្រុង ដែលសាមីខ្លួនបានសុំប្រលងពីមុន ឬអាចដាក់ពាក្យសុំប្រលងនៅតាមមន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុងផ្សេងទៀត ដោយគ្រាន់តែធ្វើសេចក្តីបញ្ជាក់ពីការប្រលងធ្លាក់ ផើពាក្យសុំប្រលងពីមន្ទីរអប់រំយុវជន និងកីឡា ខេត្ត-ក្រុង ដែលសាមីខ្លួនបានប្រលងធ្លាក់ពីមុន ។

* **កំណត់សំគាល់ :**

- ចំនួនអាវុទ្ធមានត្រូវគិតចាប់ពីបវេសនកាល រហូតដល់ថ្ងៃដែលសិស្សដាក់ពាក្យសុំប្រលង ។
- លោកនាយកសាលា :

* ត្រូវពិនិត្យសំណុំលិខិតដាក់ពាក្យសុំប្រលងរបស់សិស្ស ដោយផ្ទៀងផ្ទាត់អោយបានត្រឹមត្រូវ នូវឈ្មោះ ថ្ងៃ .......ខែ.......ឆ្នាំ កំណើត ទីកន្លែងកំណើត ឈ្មោះឪពុក ម្តាយរបស់សិស្សដែលសរសេរក្នុងពាក្យសុំប្រលង និងសលាកបត្រឯកត្តជន និងអត្តសញ្ញាណប័ណ្ណ •។ ពាក្យសុំប្រលង និងសលាកប័ត្រឯកត្តជន របស់សិស្ស ត្រូវសរសេរអោយច្បាស់តួអក្សរ ហើយមិនត្រូវសរសេរត្រួត ឬ កោសលុបឡើយ ។ បើមានករណីបែបនេះត្រូវអោយសិស្សសរសេរសាជាថ្មីឡើងវិញ ។

* ត្រូវចុះហត្ថលេខា និង បោះត្រាលើសលាកប័ត្រពិន្ទុប្រចាំឆ្នាំ របស់បេក្ខជន (បេក្ខជនម្នាក់បំពេញបួនច្បាប់ ) ដែលសរសេរបំពេញដោយផ្ទាល់ដៃសិស្ស ជៀសវាងការកោសលុប ឬសរសេរត្រួត ។

* ត្រូវណែនាំអោយសិស្សសរសេរសំណុំលិខិតដាក់ពាក្យសុំប្រលងដោយខ្លួនឯង ចៀសវាងប្រមូលយកទៅអោយអនុរក្ស ឬ គ្រូទទួលបន្ទុកថ្នាក់ ឬមិត្តភក្តិសរសេរជំនួស ។

បន្ទាប់ពីឈប់ទទួលពាក្យសុំប្រលង ត្រូវរាប់ចំនួនសិស្សដាក់ពាក្យសុំប្រលងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និង ចំនួនសិស្សដាក់ពាក្យសុំប្រលងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ផ្ញើទៅមន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុង ដើម្បីមន្ទីរធ្វើសំណើកំណត់មណ្ឌលប្រលង ផ្ញើទៅក្រសួងអប់រំយុវជន និងកីឡា ទាន់ពេលវេលា ។ ឯសំណុំលិខិតផ្សេងៗ ត្រូវផ្ញើទៅមន្ទីរអប់រំយុវជននិងកីឡា ជាបន្តបន្ទាប់ ។

## II ការកំណត់មណ្ឌលប្រឡង :

កន្លងមកគ្រឹះស្ថានសិក្សាមួយចំនួនតាមខេត្ត-ក្រុង ដែលយកធ្វើជាមណ្ឌលប្រលង ពុំទាន់បានរៀបចំអោយអស់លទ្ធភាព ដើម្បីធានាអោយដំណើរការប្រលងប្រព្រឹត្តទៅបានល្អប្រសើរនៅឡើយ ។

ដូច្នេះលោកប្រធានមន្ទីរអប់រំ យុវជននិងកីឡា ត្រូវជ្រើសរើសយកគ្រឹះស្ថានសិក្សាណា ដែលមានរបងព័ទ្ធជុំវិញ មាត់ច្រកចេញ-ចូល មានសោចាក់ត្រឹមត្រូវ ដើម្បីធ្វើជាមណ្ឌលប្រលង និងត្រូវណែនាំអោយនាយកគ្រឹះស្ថានដែលគ្រឹះស្ថានសិក្សារបស់ខ្លួន យកធ្វើជាមណ្ឌលប្រលង សំអាតទីធ្លា អាគារ បន្ទប់អនាម័យ អោយហើយស្រេចមុនដំណើរការប្រលង ។ បន្ទប់ប្រលងនីមួយៗត្រូវរៀបចំអោយមានតុ ជើងម៉ាម៉ាទាំ ដើម្បីអោយបេក្ខជនងាយស្រួលក្នុងការសរសេរកិច្ចការ ។ បើតុ ជើងម៉ាពុំមាំទាំ ត្រូវជួសជុល ឬ រកតុជើងម៉ាថ្មីមកប្តូរ ។

មណ្ឌលប្រលងនីមួយៗត្រូវមានប្រដាប់បំពងសំឡេងដែលអាចប្រើប្រាស់បាន នៅពេលដំណើរការប្រលង ។ បុគ្គលិកពីរនាក់រក្សាទុកប្រចាំគ្រឹះស្ថានសិក្សា ដែលត្រូវយកធ្វើជាមណ្ឌលប្រលង ត្រូវជ្រើសរើសក្នុងចំណោមបុគ្គលិកដែលចេះប្រើប្រាស់ និងរៀបចំប្រដាប់បំពង សំឡេង ហើយសកម្មក្នុងការដោះស្រាយកង្វះខាតសំភារៈផ្សេងៗ ។

ហាមលក់ដូរដាច់ខាតក្នុងមណ្ឌលប្រលង ក្នុងរយៈពេលដំណើរការកិច្ចការប្រលង ។

ត្រូវធ្វើការកំណត់មណ្ឌលប្រលងទៅនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ អោយបានមុនថ្ងៃ ៣០ ឧសភា ១៩៩៩ ។ (ជូនភ្ជាប់គំរូតារាងកំណត់មណ្ឌលប្រលង ) ។

## IV- សំណើប្រធានវិញ្ញាសាប្រលង :

លោកគ្រូ អ្នកគ្រូបង្រៀនថ្នាក់ទី១២ ឬបង្រៀនថ្នាក់ទី៩ នៃមធ្យមសិក្សា ត្រូវធ្វើសំណើប្រធានវិញ្ញាសាតាមមុខវិជ្ជាប្រលង ចំនួនមួយប្រធានវិញ្ញាសា សំរាប់មធ្យមសិក្សាទុតិយភូមិ និងមួយប្រធានវិញ្ញាសា សំរាប់មធ្យមសិក្សាបឋមភូមិ ដោយភ្ជាប់អត្រាកំណែមកជាមួយ ដើម្បីអោយក្រសួងពិចារណា និងជ្រើសរើស ។

លោកគ្រូ អ្នកគ្រូដែលមានភារកិច្ចធ្វើសំណើប្រធានវិញ្ញាសា ត្រូវរក្សាអោយបានម៉ឺងម៉ាត់នូវការសំងាត់ និងតម្លៃនៃមុខវិជ្ជារបស់ខ្លួន និងទទួលខុសត្រូវចំពោះមុខក្រសួង ។

ផ្នែកខាងលើនៃសំណើប្រធានវិញ្ញាសានីមួយៗ ត្រូវសរសេរតាមគំរូជូនភ្ជាប់ ។ សំណើប្រធានវិញ្ញាសានីមួយៗ ត្រូវដាក់ក្នុងស្រោមសំងាត់ ដោយបញ្ជាក់មុខវិជ្ជាលើស្រោមនោះ ។

នាយកវិទ្យាល័យ អនុវិទ្យាល័យ ត្រូវប្រមូលស្រោមសំណើប្រធានវិញ្ញាសាទាំងអស់ដាក់ក្នុងស្រោមសំងាត់រួម រួចផ្ញើទៅនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ តាមរយៈមន្ទីរអប់រំយុវជននិងកីឡា ខេត្ត-ក្រុង អោយបានមុនថ្ងៃ ២៤ ឧសភា ១៩៩៩ ។

ចំពោះវិញ្ញាសាដែលត្រូវធ្វើសំណើមានដូចតទៅ :

ក-<u>សំរាប់ការប្រលងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ</u> :

១-តែងសេចក្តី .................. រយៈពេល ២ ម៉ោង ត្រូវបានពិន្ទុពី ០ ដល់ ១០០

២-គណិតវិទ្យា .................. រយៈពេល ២ ម៉ោង ត្រូវបានពិន្ទុពី ០ ដល់ ១០០

៣-រូបវិទ្យា .................. រយៈពេល ៥០នាទី ត្រូវបានពិន្ទុពី ០ ដល់ ៣៥

៤-គីមី .................. រយៈពេល ៥០នាទី ត្រូវបានពិន្ទុពី ០ ដល់ ៣៣

៥-ជីវវិទ្យា .................. រយៈពេល ៥០នាទី ត្រូវបានពិន្ទុពី ០ ដល់ ៣៣

៦-ទស្សនវិទ្យា .................. រយៈពេល ៥០នាទី ត្រូវបានពិន្ទុពី ០ ដល់ ៣៥

៧-ប្រវត្តិវិទ្យា .................. រយៈពេល ៥០នាទី ត្រូវបានពិន្ទុពី ០ ដល់ ៣៣

៨-ភូមិវិទ្យា .................. រយៈពេល ៥០នាទី ត្រូវបានពិន្ទុពី ០ ដល់ ៣៣

ខ-សំរាប់ការប្រលងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ :

១-ភាសាខ្មែរ .............. រយៈពេល ១ ម៉ោងកន្លះ ត្រូវបានពិន្ទុពី ០ ដល់ ១០០

២-គណិតវិទ្យា .................. រយៈពេល ១ ម៉ោង ត្រូវបានពិន្ទុពី ០ ដល់ ១០០

៣-រូបវិទ្យា និងគីមី ............. រយៈពេល ៣០នាទី ត្រូវបានពិន្ទុពី ០ ដល់ ៥០

៤-ជីវវិទ្យា និងផែនដីវិទ្យា ...... រយៈពេល ៣០នាទី ត្រូវបានពិន្ទុពី ០ ដល់ ៥០

៥-ប្រវត្តិវិទ្យា និងភូមិវិទ្យា ...... រយៈពេល ៣០នាទី ត្រូវបានពិន្ទុពី ០ ដល់ ៥០

៦-សីលធម៌-ពលរដ្ឋវិជ្ជា ......... រយៈពេល ៣០នាទី ត្រូវបានពិន្ទុពី ០ ដល់ ៥០

៧-ភាសាបរទេស ...............រយៈពេល ៤៥នាទី ត្រូវបានពិន្ទុពី ០ ដល់ ៥០

**V- ការផ្តល់ពិន្ទុប្រចាំឆ្នាំទៅក្រសួង :**

នាយកវិទ្យាល័យ - អនុវិទ្យាល័យ និងសាលារៀនក្រោមឱវាទផ្ទាល់ក្រសួង ត្រូវផ្ញើទៅក្រសួង (នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ) តាមរយៈមន្ទីរអប់រំយុវជន និងកីឡាខេត្ត-ក្រុង នូវ ៖

ក-បញ្ជីមធ្យមភាគពិន្ទុប្រចាំឆមាសទី១ របស់សិស្សថ្នាក់ទី៩ និងទី១២ អោយបានមុនថ្ងៃទី ២៧ មីនា ១៩៩៩ (តាមគំរូជូនភ្ជាប់)

ខ-បញ្ជីពិន្ទុប្រចាំឆ្នាំ របស់សិស្សថ្នាក់ទី៩ និងទី១២ អោយបានមុន ថ្ងៃទី ៣០ មិថុនា ១៩៩៩ (តាមគំរូជូនភ្ជាប់) ។

លោកប្រធានមន្ទីរអប់រំយុវជន និងកីឡាគ្រប់ខេត្ត-ក្រុង ត្រូវផ្សព្វផ្សាយការណែនាំនេះដល់គ្រប់គ្រឹះស្ថានមធ្យមសិក្សាក្រោមឱវាទ ដើម្បីអោយការអនុវត្តន៍មានប្រសិទ្ធភាព ។

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

ហត្ថលេខា និងត្រា

**តុល ឡោះ**

★★★

## បញ្ជីពិន្ទុប្រចាំឆ្នាំ

***

| លរ | គោត្តនាមនិងនាម | ថ្ងៃ ខែ ឆ្នាំកំណើត | ថ្នាក់ | មធ្យមភាគពិន្ទុប្រចាំឆមាសទី១ | មធ្យមភាគពិន្ទុប្រចាំឆមាសទី២ | ពិន្ទុប្រចាំឆ្នាំ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១ | ក | ០៣-៧-៨៤ | ៩គ | ៣០,២៧ | ៣៥,៨៧ | ៦៥,១៥ | |
| ២ | ខ | ១០-៥-៨៤ | ៩ខ | ៤០,៣៦ | ៣៥,១៦ | ៦៨,១៦ | |
| ៣ | គ | ២២-០២-៨៥ | ៩ក | ៤០,៣៦ | ៣៧,៨២ | ៧៨,១៨ | |
| ..... | ក.គឹម សុភាព | ០១-៦-៨២ | ៩ង | ២៥,១៥ | A | ......... | បោះបង់ការសិក្សា |
| ..... | ..................... | ................. | ...... | .................... | ............... | ........... | ........... |
| ..... | ..................... | ................. | ...... | .................... | ............... | ........... | ........... |
| ..... | ស់ សាន | ០៧-៨-៨១ | ៩គ | A | A | .......... | ឈឺ |
| ..... | ..................... | ................. | ...... | .................... | ............... | ........... | ........... |
| ..... | ..................... | ................. | ...... | .................... | ............... | ........... | ........... |

បញ្ឈប់បញ្ជីចំនួនសិស្ស ................នាក់

បានឃើញ និង ឯកភាព ...........ថ្ងៃទី...... ខែ.......... ឆ្នាំ ១៩៩៨

ប្រធានមន្ទីរអប់រំយុវជន និងកីឡា នាយកវិទ្យាល័យ-អនុវិទ្យាល័យ

................... .................

## កំណត់សំគាល់

=====

១-បញ្ជីនេះត្រូវរៀបចំតាមលំដាប់អក្ខរក្រម ។

២-លេខរៀងរបស់សិស្សក្នុងបញ្ជីពិន្ទុប្រចាំឆ្នាំ ត្រូវអោយដូចលេខរៀងរបស់សិស្សក្នុងបញ្ជីមធ្យមភាគពិន្ទុប្រចាំឆមាសទី១ ។

ដូចនេះសាលារៀនអាចរៀបចំបញ្ជីនេះតែមួយលើកសំរាប់ចុះមធ្យមភាគពិន្ទុប្រចាំឆមាសទី១ រួចទុកប្រើប្រាស់សំរាប់ចុះពិន្ទុប្រចាំឆមាសទី២ និងពិន្ទុប្រចាំឆ្នាំ ។

៣-សំរាប់ថ្នាក់ទី១២ ក៏ត្រូវរៀបចំតាមតារាងគំរូនេះដែរ ។

៤-នៅពេលផ្ញើបញ្ជីមធ្យមភាគពិន្ទុប្រចាំឆមាសទី១ របស់សិស្សថ្នាក់ទី១២ ទៅនាយកដ្ឋានមធ្យមសិក្សា ចំនេះទូទៅ វិទ្យាល័យនីមួយៗ ត្រូវផ្ញើវិញ្ញាបនបត្របណ្ដោះអាសន្នមធ្យមសិក្សាបឋមភូមិរបស់សិស្សថ្នាក់ទី១២ ភ្ជាប់មកជាមួយផងសំរាប់ផ្ទៀងផ្ទាត់បេក្ខភាព ។ ចំពោះបញ្ជីមធ្យមភាគពិន្ទុប្រចាំឆមាសទី១

របស់សិស្សថ្នាក់ទី៩ វិទ្យាល័យ-អនុវិទ្យាល័យនីមួយៗ ត្រូវបញ្ជាក់ពីចំនួនសិស្សសរុបរៀនភាសាបារាំង និងចំនួនសិស្សសរុបរៀនភាសាអង់គ្លេសផង ។

៥-ក្នុងពេលសិក្សា បើសិនជាសិស្សណើ ឬមានគ្រោះថ្នាក់មិនបានប្រលងឆមាស ប៉ុន្តែមានលិខិតបញ្ជាក់ត្រឹមត្រូវ គណៈគ្រប់គ្រងសាលាត្រូវបង្កលក្ខណៈអោយសិស្សបានធ្វើការប្រលងឆមាសនៅពេលចូលរៀនវិញ ។

៦-នាយកសាលារៀនត្រូវបញ្ជូនព្រឹត្តិបត្រពិន្ទុរបស់សិស្សថ្នាក់ទី៩ ទី១២ ដែលបានពិន្ទុប្រចាំឆ្នាំ ចាប់ពី ៧៥ពិន្ទុឡើងទៅ ទៅមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ហើយមន្ទីរផ្ញើព្រឹត្តិបត្រពិន្ទុរបស់សិស្សទាំងនេះទៅនាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ ដើម្បីផ្ទៀងផ្ទាត់ពិន្ទុតាមមុខវិជ្ជានៅពេលប្រលងថ្នាក់ជាតិ ។ ក្រសួងនឹងបង្កើតគណៈកម្មការ ដើម្បីត្រួតពិនិត្យបញ្ហានេះ ។

★★★

រាជធានីភ្នំពេញ,ថ្ងៃទី០៤ ខែ មីនា ឆ្នាំ ១៩៩៩

# សារាចរណែនាំ លេខ ០២ អយក.សរណន

## ស្តីពី

## ការរៀបចំប្រលងសញ្ញាប័ត្រចំនេះទូទៅ និងបំពេញវិជ្ជា

***

-យោងប្រកាសលេខ ១៤៩ និងលេខ ១៥៣ អយក/ប្រក របស់ក្រសួងអប់រំយុវជន និងកីឡា ចុះថ្ងៃទី០៤ និង០៩ មីនា ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃការប្រលងសញ្ញាបត្រមធ្យម សិក្សាបឋមភូមិ និងទុតិយភូមិ ។

-យោងកម្មវិធីការងារប្រឡងផ្នែកចំនេះទូទៅ សំរាប់ដំណាច់ឆ្នាំសិក្សា ១៩៩៨-១៩៩៩ ចុះថ្ងៃទី ០១ ខែ មីនា ១៩៩៩ ដើម្បីអោយការប្រលងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិមានលក្ខណៈកាន់តែល្អប្រសើរ ក្រសួងអប់រំយុវជន និងកីឡា សូមធ្វើការណែនាំដូចតទៅ :

### I- យន្តការសំរាប់រៀបចំការប្រលង :

#### ១- សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ :

-ខេត្ត-ក្រុងគ្រប់គ្រងផ្ទាល់ការប្រលង តែក្រសួងនឹងចាត់មន្ត្រីពីក្រសួងទៅធ្វើអប្បមាទក្នុងមួយមណ្ឌលសំនេរមួយនាក់ ។

-សមាសភាពនៃគ្រប់គណៈកម្មការមេប្រយោគ សុទ្ធតែជាមន្ត្រីអប់រំនៅក្នុងខេត្ត-ក្រុង គ្រាន់ធ្វើការផ្លាស់ប្តូរមេប្រយោគ ពីស្រុកមួយទៅស្រុកមួយទៀតដែលនៅជិតៗគ្នាក្នុងខេត្ត-ក្រុង ។

-មន្ត្រីក្រសួងអប់រំយុវជន និងកីឡា ធ្វើជាអប្បមាទតាមគ្រប់មណ្ឌលសំនេររបស់ខេត្ត-ក្រុង ។

-មេប្រយោគទូទាំងប្រទេស មានភារកិច្ចចុះត្រួតពិនិត្យការអនុវត្តនីការងារប្រលងតាមខេត្ត-ក្រុង នីមួយៗ ។

២-សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ :

-ក្រសួងគ្រប់គ្រងការប្រលង

-សមាសភាពគណៈកម្មការអនុរក្ស និងគណៈកម្មការកណ្តាល គឺជ្រើសរើសមន្ត្រីអប់រំ ក្នុងខេត្ត-ក្រុងមិនផ្លាស់ប្តូរពីខេត្ត-ក្រុងមួយទៅខេត្ត-ក្រុងមួយទៀត ។

-ប្រធាន-អនុប្រធានមណ្ឌល អប្បមាទ និងគណៈកម្មការត្រួតពិនិត្យអគារ ធ្វើការផ្លាស់ប្តូរពីខេត្ត-ក្រុងមួយទៅខេត្ត-ក្រុងមួយទៀត ។

-គណៈកម្មការកំនែ គណៈកម្មការបែងចែកសន្លឹកប្រលង គណៈកម្មការស្រង់បូកពិន្ទុ និងចុះជាប់ធ្លាក់ត្រូវមកពីខេត្ត-ក្រុង ដើម្បីបំពេញការងារនៅមណ្ឌលកំនែប្រមូលផ្តុំនៅភ្នំពេញ ។ គណៈកម្មការនានា សំរាប់ដំណើរការប្រលង រៀបចំដូចការប្រលងនាឆ្នាំកន្លងមក គ្រាន់តែមុនពេលដំណើរការប្រលងខេត្ត-ក្រុងនីមួយៗ ត្រូវបង្កើតគណៈកម្មការសំរាប់ធ្វើលិខិតឧទ្ទេសនាម (តាមគំរូ និងនិយាមដូចមានជូនភ្ជាប់) ។

II- ដំណើរការប្រព្រឹត្តទៅនៃការប្រលង :

១- សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ : (ដំណើរការវិញ្ញាសាសរសេរមួយថ្ងៃ)

- ថ្ងៃទី១ : ដំនើរការវិញ្ញាសាសរសេរ ។

គណៈកម្មការអនុរក្ស គណៈកម្មការត្រួតពិនិត្យអគារ និងគណៈកម្មការកណ្តាលបំពេញការងារមួយថ្ងៃ (រួចរំសាយ) ។

- រសៀលថ្ងៃទី២ : ប្រជុំគណៈកម្មការក្រុមមណ្ឌលកំនែ ។

- ថ្ងៃទី ៣-៤-៥ : ចុះលេខសំងាត់លើសន្លឹកកិច្ចការបេក្ខជន ។

- ថ្ងៃទី ៦ - ៧ : ធ្វើអត្រាកំនែ និងកែកិច្ចការបេក្ខជន ។

គណៈកម្មការកំនែ និងគណៈកម្មការបែងចែកសន្លឹកកិច្ចការបេក្ខជន បំពេញការងារពីរថ្ងៃ (រួចរំសាយ) ។

-ថ្ងៃទី ៨-៩-១០ : ស្រង់បូកពិន្ទុ និងចុះជាប់ធ្លាក់ ។ គណៈកម្មការស្រង់បូកពិន្ទុ និង ចុះជាប់ធ្លាក់បំពេញការងារបីថ្ងៃ ។

-ថ្ងៃទី១០ : ប្រកាសលទ្ធផល ។

-សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ : (ដំណើរការវិញ្ញាសាសរសេរមួយថ្ងៃកន្លះ)

- ថ្ងៃទី១ - ២ : ដំនើរការវិញ្ញាសាសរសេរ ។

គណៈកម្មការអនុរក្ស គណៈកម្មការត្រួតពិនិត្យអគារ និងគណៈកម្មការកណ្តាលបំពេញការងារពីរថ្ងៃ (រួចរំសាយ) ។

- រសៀលថ្ងៃទី៣ : ប្រជុំគណៈកម្មការកណ្តាលក្រុមមណ្ឌលកំណែ ។

- ថ្ងៃទី ៤-៥-៦ : ចុះលេខសំងាត់លើសន្លឹកកិច្ចការបេក្ខជន ។
- ថ្ងៃទី ៧-៨-៩ : ធ្វើអត្រាកំនែ និងកែកិច្ចការបេក្ខជន ។

គណៈកម្មការកំនែ និងគណៈកម្មការបែងចែកសន្លឹកកិច្ចការបេក្ខជន បំពេញការងារបីថ្ងៃ (រួចរំសាយ) ។

- ថ្ងៃទី ១០-១១-១២ : ស្រង់បូកពិន្ទុ និងចុះជាប់ធ្លាក់ ។
- គណៈកម្មការស្រង់បូកពិន្ទុ និង ចុះជាប់ធ្លាក់ បំពេញការងារបីថ្ងៃ ។
- ថ្ងៃទី១២ : ប្រកាសលទ្ធផល ។

## II- និយាមប្រើប្រាស់មេប្រយោគ និងចំនួនមេប្រយោគ :

| | មេប្រយោគទូទាំងប្រទេស | មេប្រយោគទូទាំងខេត្ត | ប្រធានអនុប្រធានមណ្ឌល | អប្បមាទ | គណៈកម្មការកណ្ដាល | គណៈកម្មការត្រួតពិនិត្យអគារ | អនុរក្ស | គណៈកម្មការបែងចែកសន្លឹកកិច្ចការបេក្ខជន | អ្នកកែ | ប្រធានកំនែតាមមុខវិជ្ជា | គណៈកម្មការស្រង់បូកពិន្ទុ និងចុះជាប់ធ្លាក់ |
|---|---|---|---|---|---|---|---|---|---|---|---|
| និយាម | | | ០,១៥/បន្ទប់ | ០,១៥/បន្ទប់ | ០,៥/បន្ទប់ | ០,២៥/បន្ទប់ | ២,២៥/បន្ទប់ | ៦០នាក់ក្នុង១មណ្ឌលកំនែ | ០,៤ បន្ទប់ មុខវិជ្ជាខ្មែរ-ភូមិ-ប្រវត្តិ-និង រូបវិទ្យា-គីមី ០,២៥ / បន្ទប់ មុខវិជ្ជាផ្សេងទៀត | ១/១០ នៃអ្នកកែ តាមមុខវិជ្ជា | ០,៥/បន្ទប់ |

ការគិតចំនួនមេប្រយោគ តាមនិយាមដូចមានក្នុងតារាង នឹងមានពន្យល់លំអិតភ្ជាប់ជាមួយគំរូលិខិតឧទ្ទេសនាម គណៈកម្មការនីមួយៗ នៃមេប្រយោគប្រលង ។

## IV- ការរៀបចំលិខិតឧទ្ទេសនាមសំរាប់ការប្រលងលើកទី១ :

មន្ទីរអប់រំយុវជន និងកីឡា ខេត្ត-ក្រុង ត្រូវរៀបចំគណៈកម្មការមួយសំរាប់ធ្វើពង្រាងលិខិតឧទ្ទេសនាមមេប្រយោគប្រលង និងបញ្ជីផ្សេងៗ តាមការណែនាំដូចតទៅ :

### ក-ការប្រលងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ :

១-ពង្រាងលិខិតឧទ្ទេសនាម គណៈមេប្រយោគទូទាំងខេត្ត (គំរូទី១ជូនភ្ជាប់)

* សមាសភាពគណៈមេប្រយោគទូទាំងខេត្តមាន :

- ប្រធាន មន្ទីរអប់រំ យុវជន និងកីឡា ------------------------------------------ ប្រធាន
- អនុប្រធាន មន្ទីរអប់រំ យុវជន និងកីឡា ------------------------------------ អនុប្រធាន
- ប្រធាន ឬ អនុប្រធាន ការិ.មធ្យមសិក្សា - ការិ.ប្រលង ការិ.អប់រំក្រៅប្រព័ន្ធ ការិ.ផែនការ និង គណនេយ្យ នៃមន្ទីរអប់រំ យុវជន និងកីឡា ----------------- សមាជិក
- ប្រធាន ឬ អនុប្រធាន ការិ.អប់រំយុវជន និងកីឡាស្រុក-ខ័ណ្ឌដែលមានមណ្ឌលប្រលង ------------------------------------------------------------------ សមាជិក

២-ពង្រាងលិខិតឧទ្ទេសនាម មេប្រយោគសំរាប់ដំណើរការវិញ្ញាសាសរសេរ (គំរូទី២ជូនភ្ជាប់)

* សមាសភាពប្រធាន-អនុប្រធានមណ្ឌលប្រលង ជ្រើសរើសក្នុងចំណោម នាយក-នាយករង វិទ្យាល័យ-អនុវិទ្យាល័យ ដែលមានលក្ខណៈសម្បត្តិល្អ និង ឈ្លាសវៃ ។
* សមាសភាពគណៈកម្មការ អប្បមាទ ជ្រើសរើសក្នុងចំណោមនាយក-នាយករង វិទ្យាល័យ-អនុវិទ្យាល័យ និង ប្រធាន - អនុប្រធានការិយាល័យ នៃមន្ទីរអប់រំ យុវជន និងកីឡា ដែលមានបទពិសោធ ស្អាតស្អំល្អ និងឈ្លាសវៃ ។
* សមាសភាពគណៈកម្មការកណ្តាល ជ្រើសរើសក្នុងចំណោមបុគ្គលិកការិយាល័យ នៃ វិទ្យាល័យ-អនុវិទ្យាល័យ និង បុគ្គលិក នៃមន្ទីរអប់រំ យុវជន និងកីឡា ដែល មានគុណសម្បត្តិល្អ និងមានសមត្ថភាពផ្នែករដ្ឋបាល ។
* សមាសភាពគណៈកម្មការ អនុរក្ស ជ្រើសរើសក្នុងចំណោមលោកគ្រូ អ្នកគ្រូបង្រៀនថ្នាក់ទី៧ និងទី៨ ។
* សមាសភាពគណៈកម្មការត្រួតពិនិត្យអគារ ជ្រើសរើសក្នុងចំណោមបុគ្គលិកការិយាល័យ នៃមន្ទីរអប់រំ យុវជន និងកីឡា និងលោកគ្រូ អ្នកគ្រូ ដែលសកម្មឈ្លាសវៃ មិនចំពាក់ទាក់ទងនឹងការងារបង្រៀនថ្នាក់ទី៧ និងទី៨ ។

៣-ពង្រាងលិខិតឧទ្ទេសនាម អ្នកកែតាមមុខវិជ្ជា (គំរូទី៣ជូនភ្ជាប់)

* សមាសភាពអ្នកកែ តាមមុខវិជ្ជានីមួយៗ គឺជ្រើសរើសក្នុងចំណោម លោកគ្រូ អ្នកគ្រូ ដែលបង្រៀនថ្នាក់ទី៩ ។

ក្នុងនោះមាន :

- ប្រធាន - អនុប្រធានក្រុមបច្ចេកទេសតាមមុខវិជ្ជាមួយចំនួន-------------------ប្រធាន
- ប្រធាន - អនុប្រធានក្រុមបច្ចេកទេសតាមមុខវិជ្ជាមួយចំនួន-------------------អនុប្រធាន
- លោកគ្រូ អ្នកគ្រូ តាមមុខវិជ្ជា ------------------------------------------------សមាជិក

៤-ពង្រាងលិខិតឧទ្ទេសនាម គណៈកម្មការគ្រប់គ្រង និងបែងចែកសន្លឹកកិច្ចការប្រលង និងគណៈកម្មការស្រង់ ប្អូកពិន្ទុ និងចុះជាប់ធ្លាក់ (គំរូទី៤ជូនភ្ជាប់)

* សមាសភាពនៃគណៈកម្មការទាំងនេះ ជ្រើសរើសក្នុងចំណោម បុគ្គលិកការិយាល័យ នៃ វិទ្យាល័យ អនុវិទ្យាល័យ និងបុគ្គលិកការិយាល័យនៃមន្ទីរអប់រំ យុវជន និងកីឡា ដែលមានគុណសម្បត្តិល្អ ។

ចំពោះខេត្ត រតនគិរី - មណ្ឌលគិរី - ស្ទឹងត្រែង - ព្រះវិហារ - កោះកុង - ក្រុងកែប - ក្រុងប៉ៃលិន និងខេត្ត ដែលមានមួយក្រុមមណ្ឌលក៏នៃមិនបាច់រៀបចំគណៈកម្មការទេ ។

**ខ-ការប្រលងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ :**

១-ពង្រាងលិខិតឧទ្ទេសនាម សំរាប់ដំណើរការវិញ្ញាសាសរសេរ (គំរូទី២ជូនភ្ជាប់)

-មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុង គ្រាន់តែរៀបចំសមាសភាពគណៈកម្មការកណ្តាល និងគណៈកម្មការអនុរក្សប៉ុណ្ណោះ ។

* សមាសភាពគណៈកម្មការកណ្ដាល ជ្រើសចំរុះក្នុងចំណោមបុគ្គលិកការិយាល័យនៃគ្រប់ វិទ្យាល័យ ក្នុងខេត្ត-ក្រុង ។
* សមាសភាពអនុរក្ស ជ្រើសរើសចំរុះក្នុងចំណោមលោកគ្រូ អ្នកគ្រូ ដែលបង្រៀនថ្នាក់ទី១០ និងថ្នាក់ទី១១ នៃគ្រប់វិទ្យាល័យ ក្នុងខេត្ត-ក្រុង ។

២-ចំពោះការរៀបចំគណៈកម្មការមេប្រយោគផ្សេងទៀត ក្រសួងអប់រំ យុវជន និងកីឡា ជាអ្នករៀបចំ មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុង គ្រាន់តែរៀបចំបន្ថែមនូវ :

២-១ បញ្ជីរាយនាមប្រធាន - អនុប្រធានមន្ទីរអប់រំយុវជន និងកីឡា ប្រធាន - អនុប្រធានការិយាល័យមធ្យមសិក្សា - ការិយាល័យប្រលង - ការិយាល័យអប់រំក្រៅប្រព័ន្ធ (គំរូទី៦ជូនភ្ជាប់) ។

២-២ សំណើប្រធាន - អនុប្រធានមណ្ឌល និងអប្បមាទតាមគំរូ និងនិយាមដែលបានកំនត់ ដោយគិតតាមចំនួនបន្ទប់សរុបក្នុងខេត្ត-ក្រុង ។

ប្រធាន - អនុប្រធានមណ្ឌលជ្រើសរើសក្នុងចំណោមនាយក-នាយករងវិទ្យាល័យ ។

អប្បមាទ ជ្រើសរើសក្នុងចំណោម នាយក-នាយករង វិទ្យាល័យ ប្រធាន - អនុប្រធានការិយាល័យមធ្យមសិក្សា - ការិយាល័យប្រលង និង ការិយាល័យអប់រំក្រៅប្រព័ន្ធ (គំរូទី៧ ជូនភ្ជាប់) ។

២-៣ បញ្ជីរាយនាមអ្នកស្រង់-បូកពិន្ទុ និងចុះជាប់ធ្លាក់ ដោយគិតតាមនិយាម ០,៣ ក្នុងមួយបន្ទប់ (គំរូទី៨ ជូនភ្ជាប់ )

អ្នកស្រង់បូកពិន្ទុ និង ចុះជាប់ធ្លាក់ ជ្រើសរើសក្នុងចំណោមបុគ្គលិកការិយាល័យដែលរហ័សរហួន-ឈ្លាសវៃ ក្នុងការស្រង់ និងបូកពិន្ទុ ។

២-៤ បញ្ជីរាយនាមនិងសលាកប័ត្រពត៌មានរបស់គ្រូបង្រៀនថ្នាក់ទី១២ តាមមុខវិជ្ជា (គំរូទី៩ និងទី១០ជូនភ្ជាប់)

២-៥ បញ្ជីរាយនាមអ្នកត្រួតពិនិត្យអគារ ។ អ្នកត្រួតពិនិត្យ អគារ ជ្រើសរើសក្នុងចំណោមបុគ្គលិកការិយាល័យ នៃមន្ទីរអប់រំយុវជន និងកីឡា និងលោកគ្រូ អ្នកគ្រូ ដែលបង្រៀនថ្នាក់ទី១០ និងទី១១ នៃវិទ្យាល័យក្នុងខេត្ត-ក្រុង ដែលឈ្លាសវៃ និងម៉ឺងម៉ាត់ក្នុងការងារ តាមនិយាម ០,១៥ ក្នុងមួយបន្ទប់ (គំរូទី១១ជូនភ្ជាប់) ។ ការជ្រើសរើសលោកគ្រូ អ្នកគ្រូបង្រៀនថ្នាក់ទី១០ និងទី១១ ត្រូវជ្រើសរើសចំរុះអោយបានគ្រប់វិទ្យាល័យ ។

## V- ការផ្ញើសំណុំលិខិត :

មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុង ត្រូវផ្ញើទៅនាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ អោយបានមុនថ្ងៃទី១៥ មិថុនា ១៩៩៩ នូវ :

១-ពង្រាងលិខិតឧទ្ទេសនាមគណៈមេប្រយោគ ទូទាំងខេត្ត (សមបភ)

២-ពង្រាងលិខិតឧទ្ទេសនាមមេប្រយោគ សំរាប់ដំណើរការវិញ្ញាសាសរសេរ (សមបភ)

៣-ពង្រាងលិខិតឧទ្ទេសនាមអ្នកកែតាមមុខវិជ្ជា (សមបភ)

៤-ពង្រាងលិខិតឧទ្ទេសនាមគណៈកម្មការគ្រប់គ្រង និង បែងចែកសន្លឹកកិច្ចការប្រលង និង គណៈកម្មការស្រង់ ប្ដូរពិន្ទុ និងចុះជាប់ ធ្លាក់ (សមបភ)

៥-សំណើប្រធាន - អនុប្រធានមណ្ឌលប្រលងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ ( គំរូទី៥ ជូនភ្ជាប់ )

៦-ពង្រាងលិខិតឧទ្ទេសនាមសំរាប់ដំណើរការវិញ្ញាសាសរសេរ (សមទភ) ។

៧-បញ្ជីរាយនាមប្រធាន - អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុង ប្រធាន - អនុប្រធានការិយាល័យ : មធ្យមសិក្សា - ប្រលង - អប់រំក្រៅប្រព័ន្ធ នៃមន្ទីរអប់រំ យុវជន និងកីឡា (សមទភ) ។

៨-សំនើប្រធាន - អនុប្រធានមណ្ឌល និង អប្បមាទ (សមទភ)

៩-បញ្ជីរាយនាមអ្នកស្រង់-ប្ដូរពិន្ទុ និងចុះជាប់ធ្លាក់ (សមទភ)

១០-បញ្ជីរាយនាម និងសលាកប័ត្រពត៌មានរបស់គ្រូបង្រៀនថ្នាក់ទី១២ តាមមុខវិជ្ជា (សមទភ)

១១-បញ្ជីរាយនាមអ្នកត្រួតពិនិត្យអគារ (សមទភ)

១២-ស្ថិតិ វិទ្យាល័យ - អនុវិទ្យាល័យ (គំរូទី១២ ជូនភ្ជាប់ )

១៣-បញ្ជីរាយនាមនាយកវិទ្យាល័យ (គំរូទី១៣ ជូនភ្ជាប់ )

១៤-បញ្ជីរាយនាមនាយករងវិទ្យាល័យ (គំរូទី១៤ ជូនភ្ជាប់ )

១៥-បញ្ជីរាយនាមនាយកអនុវិទ្យាល័យ (គំរូទី១៥ ជូនភ្ជាប់ )

១៦-បញ្ជីរាយនាមនាយករងអនុវិទ្យាល័យ (គំរូទី១៦ ជូនភ្ជាប់ )

១៧-លិខិតឧទ្ទេសនាមគណៈកម្មការ ធ្វើពង្រាងលិខិតឧទ្ទេសនាម (គំរូទី១៧ ជូនភ្ជាប់ )

## VI- ការរៀបចំប្រលងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និង ទុតិយភូមិលើកទី២ :

### ១-ការកំណត់មណ្ឌលប្រលង :

ក្រោយប្រកាសលទ្ធផលប្រលងលើកទី១ មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុង ត្រូវរៀបចំជាបន្ទាន់ នូវសំនើមណ្ឌលប្រលងលើកទី២ ហើយផ្ញើសំនើមណ្ឌលទាំងនោះ ទៅនាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅអោយបានមុនថ្ងៃទី០៦ ខែ សីហា ១៩៩៩ សំរាប់ការប្រលងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិលើកទី២ និងមុនថ្ងៃទី ២២ ខែសីហា ១៩៩៩ សំរាប់ការប្រលងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិលើកទី២ (យកតាមគំរូកំណត់មណ្ឌលប្រលង ក្នុងសារាចរណែនាំលេខ ០១ អយក សរណន ចុះថ្ងៃទី ០៤ មីនា ១៩៩៩ ស្ដីពី**ការប្រលងបញ្ចប់គ្រប់ភូមិសិក្សាផ្នែកចំនេះទូទៅ- បំពេញវិជ្ជាសាធារណៈ និងឯកជន** ) ។

### ២-ពង្រាងលិខិតឧទ្ទេសនាម :

គ្រប់ពង្រាងលិខិតឧទ្ទេសនាម គណៈមេប្រយោគប្រលងទាំងពីរភូមិសិក្សា ត្រូវរៀបចំដូចពង្រាងលិខិតឧទ្ទេសនាមដែលបានណែនាំសំរាប់ការប្រលងលើកទី១ ។ ពង្រាងលិខិតឧទ្ទេសនាម

សំរាប់ការប្រលងលើកទី២នេះ ត្រូវផ្ញើទៅនាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ អោយបានមុនថ្ងៃទី១៥ សីហា ១៩៩៩ សំរាប់ការប្រលងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ដោយភ្ជាប់មកជាមួយនូវសំណើប្រធាន អនុប្រធានមណ្ឌល និងអប្បមាទ បញ្ជីរាយនាមអ្នកត្រួតពិនិត្យអាគារ ព្រមទាំងបញ្ជីរាយនាម អ្នកស្រង់-ប្តូកពិន្ទុ-ចុះជាប់ធ្លាក់ ដែលមានសមាសភាព និងនិយាមដូចការណែនាំប្រលងលើកទី១ និងអោយបានមុនថ្ងៃទី ០៤ កញ្ញា ១៩៩៩ សំរាប់ការប្រលងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ដោយភ្ជាប់មកជាមួយនូវសំនើប្រធាន-អនុប្រធានមណ្ឌលតាមគំរូទី៥ ជូនភ្ជាប់ ។

* **កំណត់សំគាល់ :**

ក-សាលារៀនក្រោមឱវាទផ្ទាល់ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបញ្ជូនបញ្ជីឈ្មោះនាយក- នាយករង បុគ្គលិកបង្រៀន និងបុគ្គលិកការិយាល័យនៃវិទ្យាល័យ - អនុវិទ្យាល័យ និងពាក្យសុំប្រលងរបស់បេក្ខជន ទៅមន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ ។

ខ-គណៈកម្មការធ្វើពង្រាងលិខិតឧទ្ទេសនាមរបស់ខេត្ត-ក្រុង (គំរូទី១៧) ត្រូវរៀបចំចំនួនតាមនិយាម ដូចខាងក្រោម :

| ល.រ | ខេត្ត-ក្រុង | គណៈកម្មការរៀបចំប្រលងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ | គណៈកម្មការរៀបចំប្រលងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ |
|---|---|---|---|
| ១ | ធំ | ១០ | ៥ |
| ២ | មធ្យម | ៦ | ៣ |
| ៣ | តូច | ២ | ១ |

-ខេត្តធំមាន៦គឺ រាជធានីភ្នំពេញ - កណ្តាល - កំពង់ចាម - បាត់ដំបង - តាកែវ និងព្រៃវែង

-ខេត្តតូចមាន៧គឺ ក្រុងកែប - ស្ទឹងត្រែង - មណ្ឌលគិរី - រតនគិរី - កោះកុង - ព្រះវិហារ ក្រុងប៉ៃលិន

ក្រសួងសង្ឃឹមថា លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡាគ្រប់ខេត្ត-ក្រុង នឹងខិតខំអនុវត្តការណែនាំនេះអោយមានប្រសិទ្ធភាពខ្ពស់ ។

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

ហត្ថលេខា និងត្រា

តុល ឡោះ

***

# ៥-នីស្តីការដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាល និង យុវនីតិសម្បទា

## ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

## ប្រកាស លេខ ៨០ សកបយ

## ស្តីពី

## ការធ្វើការបន្ថែមម៉ោងក្រៅពីថិរវេលាធ្វើការធម្មតា

* * *

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញច្បាប់ស្តីពីការងារដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ជស/រកម/០៣៩៧ / ០១ ចុះថ្ងៃទី១៣ ខែ មីនា ឆ្នាំ ១៩៩៧

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤

## សំរេច

**ប្រការ១** : ម្ចាស់ ឬ នាយកសហគ្រាស គ្រឹះស្ថានដែលស្ថិតក្នុងដែន អនុវត្ត នៃច្បាប់ ស្តីពីការងារអាច ស្នើសុំការអនុញ្ញាតពីក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ដើម្បីធ្វើការបន្ថែមម៉ោងលើសពីថិរវេលាធ្វើការធម្មតា របស់សហគ្រាសគ្រឹះស្ថានរបស់ខ្លួននៅក្នុងករណីដូចតទៅ ៖

ក-ដើម្បីអោយការងារពិសេសប្រព្រឹត្តទៅបានដូចជា ការធ្វើបញ្ជីសារពើភ័ណ្ឌ និងតុល្យការ ការដាក់កំណត់ពេលវេលា ការជំរះបញ្ជី និងការចញ្ឈប់គណនេយ្យ ។

ខ-ដើម្បីអោយសហគ្រាសអាចទប់ទល់នឹងការងារដែលមានច្រើនខុសធម្មតា បណ្តាលមកពីកាលៈទេសៈប្លែកៗ ដោយមិនអាចរង់ចាំនិយោជករកវិធានការដទៃផ្សេងទៀត ។

**ប្រការ២** : សំណុំលិខិតនៃការស្នើសុំធ្វើការបន្ថែមម៉ោង មានដូចតទៅ ៖

១-លិខិតស្នើសុំរបស់សហគ្រាស គ្រឹះស្ថានចំនួន០១ច្បាប់ ។

២-លិខិតបញ្ជាក់អំពីយោបល់ឯកភាពរបស់ប្រតិភូពេញសិទ្ធិគ្រប់រូបរបស់សហគ្រាស គ្រឹះស្ថាន ឬការឯកភាពពីចំនួនពាក់កណ្តាលនៃកម្មករ និយោជិតបើសហគ្រាស គ្រឹះស្ថានមិនទាន់មានប្រតិភូបុគ្គលិកចំនួន ០១ច្បាប់ ។

ប្រការ៣ : សហគ្រាស គ្រឹះស្ថានទាំងអស់ដែលមានទីតាំងនៅរាជធានីភ្នំពេញ ត្រូវបញ្ជូនសំណើលិខិតទៅស្នើសុំធ្វើការបន្ថែមម៉ោង នៅនាយកដ្ឋានអធិការកិច្ចការងារ នៃក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដែលស្ថិតនៅអគារលេខ ២៨ វិថីសម្តេចព្រះធម្មលិខិតអ៊ុក ( ផ្លូវលេខ ១៨៥ ) សង្កាត់ជ័យជំនះ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ។ ចំណែកសហគ្រាស គ្រឹះស្ថានមានទីតាំង នៅតាមខេត្ត-ក្រុងដទៃទៀត ត្រូវបញ្ជូនសំណើលិខិតទៅអធិការដ្ឋានសង្គមកិច្ច ខេត្ត-ក្រុងនៃមូលដ្ឋាន ខ្លួន ។

សំណើលិខិតនៃការស្នើសុំធ្វើការបន្ថែមម៉ោង ត្រូវបញ្ជូនទៅនាយកដ្ឋានអធិកាកិច្ចការងារនៃក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ក្នុងរយៈពេលយ៉ាងតិច១៥ថ្ងៃ មុនការចាប់ផ្តើមធ្វើការបន្ថែមម៉ោង ។ ចំពោះខេត្តក្រុងដទៃទៀតក្រៅពីរាជធានីភ្នំពេញក៏ត្រូវអនុវត្តកាលកំណត់នេះដូចគ្នាដែរ ។

ប្រការ៤ : ការរៀបចំធ្វើការបន្ថែមម៉ោងនេះត្រូវផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត ពោលគឺម្ចាស់ ឬ នាយកសហគ្រាស គ្រឹះស្ថាន មិនត្រូវបង្ខិតបង្ខំ ឬដាក់វិន័យផ្សេងៗចំពោះកម្មករ និយោជិត ដែលមិនស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោងឡើយ ។

ប្រការ៥ : ម្ចាស់ ឬ នាយកសហគ្រាស គ្រឹះស្ថាន ត្រូវផ្តល់ប្រាក់ឈ្នួលធ្វើការបន្ថែមម៉ោង ជូនកម្មករ និយោជិតដូចតទៅ ៖

ក-ស្មើនឹង ១៥០ ភាគរយ (ឬ១ដងកន្លះ) នៃប្រាក់ឈ្នួលពេលធ្វើការធម្មតា ចំពោះការធ្វើការបន្ថែមម៉ោងនៅពេលថ្ងៃនៃថ្ងៃធ្វើការធម្មតា ។

ខ-ស្មើនឹង ២០០ ភាគរយ (ឬ២ដង) នៃប្រាក់ឈ្នួលពេលធ្វើការធម្មតា ចំពោះការធ្វើការបន្ថែមម៉ោងនៅពេលយប់ (ពីម៉ោង២២.០០ ទៅម៉ោង ៥.០០ ព្រឹក) ។

ប្រការ៦ : ចំពោះសហគ្រាសដែលមានកម្មករ និយោជិតធ្វើការពេលយប់ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានត្រូវផ្តល់ទីកន្លែងសំរាកទទួលទានដំណេកអោយបានសមរម្យដល់កម្មករ និយោជិតដែលចេញពីធ្វើ

ការនៅពេលយប់ ពុំនោះសោតទេត្រូវផ្តល់មធ្យោបាយសំរាប់ដឹកជញ្ជូនកម្មករ និយោជិតទៅដល់លំនៅដ្ឋានរៀងៗខ្លួនវិញ ប្រកបដោយសុវត្ថិភាពនៅពេលចប់ម៉ោងធ្វើការពេលយប់ ។

ប្រការ៧ : រាល់ការប្រព្រឹត្តិល្មើសនឹងបទប្បញ្ញត្តិ នៃប្រកាសនេះ ត្រូវពិន័យ ឬ ផ្តន្ទាទោសតាមច្បាប់ ដូចមានចែងក្នុងជំពូកទី១៦ នៃច្បាប់ស្តីពីការងារ ។

ប្រការ៨ : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី
ហត្ថលេខានិងត្រា
អ៊ិត សំហេង

★★★